# តហិសេចក្តីជូនដំណឹងដល់មាតាបិតាស្តីអំពីនិតិវិធីការពារ

មាតាបិតាជាទីគោរពនិងរាប់អាន:

មាតាបិតាទាំងអស់មានឱកាសទទួលសេចក្តីជូនដំណឹងស្តីអំពីនិតិវិធីការពារ (សេចក្តី ជូនដំណឹង) ពីព្រោះកូនរបស់លោក/អ្នក (ជាសិស្ស) ត្រូវបានគេបញ្ជូនដើម្បីធ្វើការវាយតំលៃ ឬពីព្រោះតែកូនរបស់អ្នកកំពុងតែទទួលសេវាកម្មអប់រំពិសេស ។ ប្រសិនបើកូនរបស់អ្នកមានសិទ្ធិទទួលការអប់រំពិសេសសាលារៀន ថ្នាក់ស្រុកត្រូវតែ ផ្តល់ការអប់រំសាធារណៈសមរម្យដោយឥតគិតថ្លៃដែលមានអក្សរកាត់ (FAPE)។ ដើម្បីផ្តល់ FAPE សាលារៀនថ្នាក់ស្រុកត្រូវធ្វើការជាដៃគូរជាមួយអ្នក។ អ្នកនិងក្លាយជាសមាជិករបស់ក្រុម IEP ដែលធ្វើការពិចារណាអំពីតំរូវការសំរាប់កូនរបស់អ្នក និងដើម្បីធ្វើការអភិវឌ្ឍន៍កម្មវិធីអប់រំ ឯកជន ឬ IEP សំរាប់កូនរបស់អ្នក[1] ។ IEP ត្រូវផ្តល់ការណែនាំដែលឆ្លើយតបទៅនិងតំរូវការកូនអ្នក មានដូចជា សេវាកម្មគាំទ្រដ៏ពេញលេញដើម្បីធ្វើអោយកូនអ្នកមានការរីកចំរើនក្នុងការអប់រំ និង ទទួលបាននូវចំណេះដឹង ជំនាញ និង អ្វីៗដែលចាំបាច់សំរាប់ការអភិវឌ្ឍន៍សង្គម និង ស្មារតីស្របទៅនិងការរំពឹងទុកក្នុងការអភិវឌ្ឍន៍តាមកាលប្រវត្តិ ។ សេវាកម្ម អប់រំដែល ផ្តល់ជូនកូនអ្នកត្រូវចំណាយដោយថវិការសាធារណៈ អ្នកមិនត្រូវចំណាយថវិការផ្ទាល់ខ្លួនឡើយ ។ សិស្សទាំងអស់ដែលស្ថិតនៅក្រោមការអប់រំសាធារណៈរបស់ Commonwealth មានរួមទាំងសិស្សពិការក៏មានឱកាសសិក្សារាល់មុខវិជ្ជាតាមបទដ្ឋានសិក្សារបស់រដ្ឋ Massachusetts ដែលរដ្ឋ Massachusetts ផ្តល់សិទ្ធីឯកបុគ្គលដល់ សិស្សពិការ ដែលមានលំនៅដ្ឋានជាក់លាក់ ហើយ កំពុងសិក្សានៅឯសាលាឯកជនដោយចំណាយថវិការខ្លួនឯង ហើយសិស្សនោះកំពុង ស្វែងរកសេវាកម្មអប់រំពិសេសដើម្បីមានឱកាសចូលសិក្សា FAPE។

ច្បាប់រដ្ឋ និង សហពន្ធ័ មាន សំរាប់សាលារៀនថ្នាក់ស្រុកត្រូវអនុវត្ត នៅពេលសាលាធ្វើសេចក្តីសំរេចថា តើសិស្សត្រូវមាន សិទ្ធិទទួលការអប់រំពិសេសឬមិនមានសិទ្ធិទេ ហើយ ប្រសិនបើមានសិទ្ធិទទួល សាលាត្រូវសំរេច ថាតើសិស្សត្រូវទទួលសេវាកម្មអ្វី ។ ច្បាប់ទាំងនេះមាននិតិវិធីយ៉ាងពិស្តារដើម្បីធានាអោយប្រាកដថា សិស្សនឹងត្រូវទទួលកម្មវិធី FAPE ក្នុងកំឡុងពេលដែលពួកគេទទួលការអប់រំពិសេស ។ ការអប់រំពិសេស គឺជាវិស័យអប់រំច្បាប់សិក្សាដែលមានលក្ខណៈស្មុគស្មាញ ។ សេចក្តីពិស្តារនៃច្បាប់ មានគោល បំណង សំរាប់ការពារកូនអ្នក និងដើម្បីជួយធានាថាសិស្សត្រូវទទួលសេវាកម្មអប់រំ សមរម្យ ។ អ្នកអាច ទទួលជំនួយ បន្ថែមពីការិយាល័យណែនាំរបស់សាលា ដើម្បីធ្វើអោយអ្នកយល់អំពីដំណើរការនៃការអប់រំ ពិសេសរបស់មន្ទីរអប់រំបឋមសិក្សា និង មធ្យមសិក្សា Massachusetts (ESE)- ដើម្បីធ្វើអោយមាតាបិតាយល់អំពីការបញ្ជូនកូនពិការទៅសិក្សា និង យល់អំពីការអប់រំជាលក្ខណះបុគ្គល ដ៏ពិសេស ។ ព័ត៌មានបានមកពីប្រភពទាំងនេះ និងជួយអ្នកអោយធ្វើការជាដៃគូរ ជាមួយសាលា រៀនថ្នាក់ ស្រុក ដើម្បី ធ្វើអោយ ប្រាកដប្រជាថា

1

កូនរបស់អ្នកត្រូវមានសិទ្ធិទទួល សេវាកម្មអប់រំ ពិសេស ដ៏សមរម្យ មួយ។ មន្ទីរអប់រំបឋមសិក្សា និងមធ្យមសិក្សា (ESE) ផ្សព្វផ្សាយព័ត៌មានទូលំទូលាយសម្រាប់មាតាបិតា និងតំបន់សាលា ស្ដីអំពីគេហទំព័ររបស់ខ្លួន។ មាតិកានៃគេហទំព័រនៃមន្ទីរអប់រំបឋមសិក្សា និងមធ្យមសិក្សា (ESE) រួមបញ្ចូល នៅផ្នែកចុងក្រោយនៃលិខិតជូនដំណឹងនេះ។

សេចក្ដីជូនដំណឹងនេះពាំនាំមកនូវពត៌មានដ៏សំខាន់មួយស្ដីអំពីសិទ្ធិរបស់អ្នកដែលពាក់ពន្ធ័ទៅនឹងការធ្វើផែនការផ្នែកអប់រំពិសេសសំរាប់កូនរបស់អ្នក។
និតិវិធីការពារគឺជាវិធានជាក់លាក់មួយដើម្បីធ្វើអោយប្រាកដថាអ្នកនឹងដឹងនូវអ្វីដែលសាលារៀន ថ្នាក់ស្រុកកំពុង ធ្វើការស្នើរសុំ (សេចក្ដីការជូនដំណឹង) និង អោយអ្នកយល់ព្រមនូវ ផែនការរៀបចំដោយសាលារៀនថ្នាក់ស្រុក (ការព្រមព្រៀងពីមាតាបិតា) និងព្រមទាំង ធ្វើអោយអ្នកមានឱកាសច្រើន សំរាប់ដោះស្រាយភាពមិនចុះសំរុងជាមួយសាលារៀនថ្នាក់ស្រុក (សវនាការយុត្តិធម៌) ។ និតិវិធីការពារដែលមានចែងក្នុងច្បាប់ផ្ដល់ជូននូវការការពារបន្ថែម ដូចមានចែងក្នុងឯកសារនេះស្រាប់។

យើងខ្ញុំសង្ឃឹម ថាសេចក្ដីជូនដំណឹងនេះនឹងជាជំនួយមួយសំរាប់លោក អ្នក ពីព្រោះថា លោកអ្នកមានបទពិសោធន៍ដើរតួយ៉ាងសកម្មក្នុងការអប់រំកូនរបស់អ្នក។
ឯកសារនេះ-សេចក្ដីជូនដំណឹងស្ដីអំពីនិតិវិធីការពារ ដើម្បីឆ្លើយតបទៅនឹងសំនួរខាងក្រោមនេះ


១-ដូចម្ដេចដែលហៅថា សេចក្ដីជូនដំណឹងលាយលក្ខ័អក្សរជាមុន តើអ្នកអាចទទួលសេចក្ដីជូនដំណឹងនេះនៅ
ពេលណា?
ទំព័រ ២
២-តើដូចម្ដេចដែលហៅថាការយល់ព្រមពីមាតាបិតា?
ទំព័រ ៣
៣ តើតំបន់សាលាតម្រូវឲ្យមានការវាយតម្លៃលើសំណើសុំដោយមាតាបិតាសិស្សឬទេ?
៤ តើដូចម្ដេចដែលហៅថាការវាយតំលៃលើការអប់រំដោយឯករាជ?
ទំព័រ ៥
៥ តើអ្នកអាចមើលកំណត់ត្រាសិស្សបាននៅពេលណាខ្លះ?
ទំព័រ ៦
៦ តើឪពុកម្ដាយនិងសាលារៀនត្រូវដោះស្រាយជំលោះដោយវិធីណា?
ទំព័រ៧

៧ តើអ្នកទទួលខុសត្រូវអ្វីខ្លះប្រសិនបើអ្នកអោយសិស្សចូលរៀនសាលាឯកជន និង ប្រសិនបើអ្នកគិតថាសាលារៀនថ្នាក់ស្រុកគួរតែប្រគល់ថ្លៃសាលាអោយមកអ្នកវិញ?

ទំព័រ ១៣

៨ តើត្រូវរៀបចំផែនការអ្វីខ្លះសំរាប់បញ្ជូនកូនអ្នកចេញពីសាលារៀន?

ទំព័រ ១៣

៩ តើសាលារៀនអាចដាក់វិន័យសិស្សពិការដោយវិធីណា?

ទំព័រ ១៤

១០តើអាចស្វែងរកច្បាប់ បទបញ្ជា និង ពត៌មានសំខាន់ៗនៅកន្លែងណាបាន?

ទំព័រ ១៦

អ្នកនឹងទទួលសេចក្តីជូនដំណឹងនេះមួយឆ្នាំម្តង ប្រសិនបើកូន/សិស្សរបស់អ្នកមានសិទ្ធិទទួលការសិក្សាពិសេស។ អ្នកស្នើសុំកំណត់ហេតុនេះមួយច្បាប់ពីសាលារៀននៅក្នុងស្រុក ឬ ពី ESE នៅពេលណាក៏បាន។ ឯកសារ នេះ មាននៅក្នុងគេហទំព័រ ESE: http://www.doe.mass.edu/sped/prb.

## ១-ដូចម្តេចដែលហៅថា សេចក្តីជូនដំណឹងលាយលក្ខ័អក្សរជាមុន តើអ្នកអាចទទួលសេចក្តីជូនដំណឹងនេះនៅពេលណា?_34CFR§300.9 AND 503

សាលារៀនថ្នាក់ស្រុកត្រូវផ្តល់សេចក្តីជូនដំណឹងដល់អ្នកជាលាយល័ក្ខអក្សរ នៅពេលដែលសាលា ធ្វើការស្នើរសុំ ឬ បដិសេធ ដើម្បីចាត់វិធានការពិនិត្យមើលសិស្ស-វាយតំលៃ –និងផ្តល់សេវាកម្ម ពិសេសដល់សិស្សរបស់អ្នក ឬ ដើម្បីធ្វើការផ្លាស់ប្តូរ កម្មវិធីសិក្សារបស់សិស្ស។ បទបញ្ជាសហពន្ធ័នេះត្រូវបានគេហៅថា "សេចក្តីជូនដំណឹងលាយលក្ខ័អក្សរជាមុន "សេចក្តីជូនដំណឹងនោះត្រូវ:

- ពិពត៌នាថាតើសាលារៀនថ្នាក់ស្រុកស្នើរសុំ ឬ បដិសេធអ្វី?
- ពន្យល់ថាហេតុអ្វីបានជាសាលារៀនថ្នាក់ស្រុកស្នើរសុំ ឬ បដិសេធមិនចាត់វិធានការ?
- ពិពត៌នាថាតើសាលារៀនថ្នាក់ស្រុកបានសំរេចស្នើរសុំ ឬបដិសេធមិនចាត់វិធានការដោយវិធីណា ដូចជាប្រាប់អ្នកអំពីនីតិវិធីវាយ តំលៃ ការស្ទាបស្ទង់ កំណត់ត្រា ឬ របាយការណ៍ដែលសាលាប្រើប្រាស់សំរាប់ធ្វើសេចក្តីសំរេចចិត្ត
- ពិពត៌នាអំពីជំរើសដែលត្រូវបានពិចារណា និង មូលហេតុដែលត្រូវបានបដិសេធ ដោយក្រុម (IEP) នៃកម្មវិធីសិក្សា លក្ខណះបុគ្គកលសំរាប់កូនអ្នក។

សាលារៀនថ្នាក់ស្រុក និង ផ្តល់ជូនពត៌មាននេះដល់អ្នកដោយប្រើប្រីស៉ាទំរង់បែបបទ ESE ដែលបានបង្កើតរួចជាស្រេចហើយ ពត៌មាននេះមាននៅក្នុងគេហទំព័រ របស់ ESE ឬ ក្នុងទំរង់បែបបទនោះក៏មាន ពត៌មានដូចគ្នានេះដែរ។

អ្នកត្រូវទទួលសេចក្តីជូនដំណឹងលាយល័ក្ខអក្សរនៅពេលសាលារៀនធ្វើសកម្មភាពនានាដូចជា: ស្នើរសុំធ្វើវាយ តំលៃបឋម ឬ វាយតំលៃសារជាថ្មី ស្នើរសុំថ្មី ឬស្នើរសុំការកែប្រែ IEP ស្នើរសុំធ្វើផ្លាស់ប្តូរកន្លែងសិក្សារបស់សិស្សដោយសារមូលហេតុ នៃការដាក់វិន័យ ឬ ដោយបញ្ចប់សេវាកម្មអប់រំពិសេសនេះ ។

អ្នកនឹងត្រូវទទួលសេចក្តីជូនដំណឹង ប្រសិនបើសាលារៀនរកឃើញថាកូននាក់ពុំមានសិទ្ធិទទួលការអប់រំពិសេស ឬ សាលារៀនធ្វើបដិសេធការស្នើរសុំអោយធ្វើការវាយតំលៃ ឬស្នើរសុំសេវាកម្មអប់រំពិសេសដល់សិស្ស។ សេចក្តីជូនដំណឹងរបស់សាលាត្រូវសរសេរជាភាសាដើមរបស់អ្នក ឬដោយមធ្យោយដែលអ្នកធ្លាប់ប្រើប្រាស់ លើកលែងតែមធ្យោបាយនោះមិនអាចធ្វើបាន។ ប្រសិនបើភាសាកំណើត ឬ មធ្យោបាយនោះមិនមែនជាភាសាសរសេរសាលាត្រូវថានាខុសត្រូវថា សេចក្តី ជូនដំណឹងនោះ ត្រូវបកប្រែជូនអ្នកដោយផ្ទាល់មាត់ ឬតាមមធ្យោបាយផ្សេងៗទៀត (ភាសាជានិមិត្តសញ្ញា ) ធ្វើយ៉ាងណាអោយតែ អ្នកយល់អំពីអត្ថន័យដែលមានក្នុងសេចក្តីជូនដំណឹងនោះ។

នៅពេលដែលគេជូនដំណឹងដល់អ្នកជាលាយលក្ខ័អក្សរ គេក៍ផ្តល់ពត៌មានស្តីពីនិតិវិធីការពារមួយច្បាប់ដល់អ្នក ផងដែរ ឬ ប្រសិនបើអ្នក បានទទួលសេចក្តីជូនដំណឹងនោះរួចហើយក្នុងកំឡុងឆ្នាំសិក្សា គេនឹងប្រាប់អ្នកអំពីវីធិ ដែលអ្នកអាចស្វែងរកនិតិវិធីការពារមួយច្បាប់ទៀតដោយខ្លួនឯង ។ អ្នកនឹងទទួលពត៌មានពីមនុស្សដែលអាចជួយពន្យល់អ្នកយល់អំពីច្បាប់អប់រំពិសេសរបស់រដ្ឋ និង សហពន្ធ័។

២-តើដូចម្តេចដែលហៅថាការយល់ព្រមពីមាតាបិតា?

**34CFR§300.9 AND**
**603 CMR 28.07(1)**

---

សាលារៀនប្រហែលជាមិនអាចអោយកូនអ្នកធ្វើការប្រឡងសាក ឬ ផ្តល់សេវាកម្មអ្វីពិសេសឡើយ លើកលែងតែអ្នកព្រមព្រៀង ហើយផ្តល់ការយល់ព្រមជាលាយ លក្ខ័អក្សរ ៉ កាលយល់ព្រមពីមាតាបិតា ៉ ។ សាលារៀនថ្នាក់ស្រុកត្រូវ ធ្វើការពន្យល់យ៉ាងច្បាស់ នូវអ្វី ដែលសាលារៀនស្នើរសុំសំរាប់កូនរបស់អ្នក ហើយ សុំអោយអ្នកចុះហត្ថលេខា និង ឈ្មោះរបស់អ្នក លើបែបបទព្រមព្រៀង តំបន់សាលាត្រូវតែទាក់ទងមកអ្នកដើម្បីបង្ហាញថាអ្នកយល់ព្រមតាមសំណើររបស់សាលា។ បន្ទាប់មកតំបន់សាលានឹងស្នើសុំឲ្យអ្នកចុះហត្ថលេខានៅលើទម្រង់បែបបទព្រមព្រៀងដើម្បីបង្ហាញថាអ្នកយល់ព្រមចំពោះសំណើរបស់សាលា។ នេះគឺការប្រគល់បែបបទព្រមព្រៀងពីមាតាបិតា។

ការព្រមព្រៀងនេះធ្វើដោយស្ម័គ្រចិត្ត ។ អ្នកអាចយកបែបបទព្រមព្រៀងពីមាតាបិតានេះវិញនៅពេលណាក៍បានដែរ ។ ប្រសិនបើអ្នកយកវិញ

ទោះបីជាយ៉ាងណាក៏ដោយការដកយកបែបបទព្រមព្រៀងវិញនោះនឹងអនុវត្តសំរាប់កិច្ចការនាពេលអនាគត តែប៉ុណ្ណោះ គឺមិនអនុវត្តចំពោះអ្វីដែលសំរេចរួចហើយនោះទេ ។
សាលារៀនមិនអាចយកលេះធ្វើការបដិសេធ លោកអ្នក ឬ កូនរបស់អ្នកមិនអោយទទួលសេវាកម្ម ផលប្រយោជន៍ ឬ សកម្មភាពផ្សេងៗទៀត ដោយផ្អែកលើការបដិសេធមិនយល់ព្រមរបស់អ្នកទេ។

គេមិនទាន់តម្រូវអោយអ្នកធ្វើការព្រមព្រៀងនៅឡើយទេ លុះត្រាតែសាលារៀនបញ្ចប់ ការពិនិត្យលើទិន្ន័យ មានស្រាប់ ជាផ្នែកមួយនៃ ការវាយតំលៃ ឬ បញ្ចប់ ការវាយតំលៃសិស្សសារ ជាថ្មីម្តងទៀតសិន ។ ការប្រឡងសាក ឬ វាយតំលៃ សិស្ស ត្រូវតែធ្វើចំពោះសិស្ស គ្រប់រូបដោយមិនបាច់ការព្រមព្រៀងទេ -ដូចជា MCAS ឬ ការប្រឡងសាកក្នុងថ្នាក់ ជាផ្នែកមួយនៃកម្មវិធីអប់រំទូទៅ ឬក៏ ជាការចែករំលែក ពត៌មានជាមួយ មន្ត្រីអប់រំ របស់រដ្ឋ ឬ សហព័ន្ធដែរ។

២.១ តើសាលារៀនថ្នាក់ស្រុកស្នើរសុំការព្រមព្រៀងពីអ្នកនៅពេលណា?
**34CFR§300.300 AND**
**603 CMR 28.07(1)**

---

សាលារៀននឹងស្នើរសុំការយល់ព្រមពីមាតាបិតាក្នុងកាលទេសដូចខាងក្រោម:

ធ្វើការវាយតំលៃបឋមដើម្បីកំណត់ថាតើសិស្សម្នាក់ៗមានសិទ្ធិទទួលការអប់រំពិសេសដែរទេ
សាលារៀនមិនអាចធ្វើការវាយតំលៃ
បឋមទៅលើសិស្សដើម្បីកំណត់ថាតើសិស្សនោះមានសិទ្ធិទទួលការអប់រំពិសេស និង/ឬ សេវាកម្មផ្សេងៗទៀតដោយមិនមានការព្រមព្រៀងពីអ្នកឡើយ ។ បើសិនមានការវាយតំលៃកូនរបស់អ្នក សាលារៀនត្រូវតែ ស្នើរសុំការយលព្រមពីអ្នកដើម្បីធ្វើការវាយតំលៃនោះក្នុងរយះពេលប្រាំថ្ងៃនៃថ្ងៃសិក្សា ។

ដើម្បីអនុម័តលើសេវាកម្មបឋម
បន្ទាប់ពីការវាយតំលៃបឋមចប់សព្វគ្រប់ ប្រសិនបើក្រុម (IEP)
កម្មវិធីអប់រំលក្ខណះបុគ្គលសំរេចថាកូនរបស់អ្នកមានសិទ្ធិទទួលបាននូវការអប់រំពិសេសក្រុម IEP និងស្នើរសុំការអប់រំពិសេស និងសេវាកម្មពាក់ពន្ធ័នានាសំរាប់កូនអ្នក។ អ្នកជាសមាជិក របស់ក្រុមកម្មវិធីអប់រំឯកជន (IEP) អ្នកត្រូវតែផ្តល់ការយល់ព្រម មុនពេលសាលាអាចផ្តល់ការអប់រំ ពិសេស និង សេវាកម្មនានាដល់កូនរបស់អ្នក <u>លើកទី១</u> ។ ប្រសិនបើអ្នកមិនយល់ព្រម សាលាក៏មិនអាចផ្តល់ការអប់រំពិសេស និង សេវាកម្មផ្សេងណាមួយដល់កូនរបស់អ្នកដែរ ។ អ្នកអាចទទួលយក ឬ បដិសេធសំណើរទាំងមូលក៏បាន ឬក៏ទទួលយក ឬ បដិសេធផ្នែកណាមួយនៃសំណើរនោះក៏បានដែរ ។ កម្មវិធី IEP ទាំងមូល ឬ ផ្នែកណាមួយដែលអ្នកទទួលយកត្រូវចាប់ផ្តើមភ្លាមបន្ទាប់ពីអ្នក បានទទួល យករួច ហើយ។

ធ្វើការផ្លាស់ប្តូរសេវាកម្ម កន្លែងសិក្សា ឬ ការវាយតំលៃសារជាថ្មី

ខណៈពេលដែលអ្នកព្រមទទួលយកកម្មវិធី IEP សំរាប់កូនរបស់អ្នកហើយ សាលារៀនត្រូវស្នើរសុំការព្រមព្រៀងពីអ្នក មុនពេលសាលារៀនអាចធ្វើការផ្លាស់ប្តូរសេវាកម្ម ឬ កន្លែងសិក្សា ឬ ធ្វើការវាយតំលៃសារជាថ្មី[2] ។ ប្រសិនបើអ្នកបដិសេធមិនយល់ព្រម អ្នកមានកាតព្វកិច្ច ពាក់ពន្ធ័ជាមួយសាលា ដើម្បីធ្វើការពិភាក្សាចំពោះរាល់ការជំទាស់របស់អ្នក ហើយសាលារៀនជឿជាក់ថា ការបដិសេធរបស់អ្នកគឺជាការបដិសេធមិនអោយកូនទទួលការអប់រំសាធារណៈដោយឥតបង់ថ្លៃ (FAPE) សាលាត្រូវ ស្នើរសុំអោយមាន ការសវនាការ នៅការិយាល័យនៃការជំទាស់តវ៉ាការអប់រំពិសេស- Bureau of Special Education Appeals (BSEA) ដើម្បីសុំការអនុញ្ញាត ផ្តល់សេវាកម្មអប់រំ ឬធ្វើការវាយតំលៃកូនរបស់អ្នកជាថ្មីដោយមិនចាំបាច់មានការព្រមព្រៀងពីអ្នក ។

ដើម្បីដកភារៈកិច្ចពីសមាជិកមិនអោយចូលរួមប្រជុំ សមាជិករបស់ក្រុម IEP អាចរួចផុតភារៈកិច្ចដោយមិនបាច់ចូលរួមប្រជុំជាមួយក្រុមការងារទេ ប្រសិនបើអ្នកយល់ព្រមដោយលាយលក្ខ័អក្សរមុនពេលប្រជុំចាប់ផ្តើម ។ ប្រសិនបើក្រុមការងារធ្វើការពិភាក្សាអំពីសមាជិកដែលមិនមានភារៈកិច្ច សមាជិករូប នោះត្រូវផ្តល់យោបល់របស់ខ្លួនជាលាយលក្ខ័អក្សរអោយបានមុនការប្រជុំក្រុមការងារចាប់ផ្តើម។ ប្រសិនបើអ្នកមិនយល់ព្រមដកភារៈកិច្ចសមាជិកក្រុមណាម្នាក់ទេ សមាជិកនោះត្រូវតែចូលរួមប្រជុំដែរ។

## ២.២ តើការស្នើរសុំការយល់ព្រមពីសិស្សនៅពេលណា?

**34CFR§300.520 AND**
**603 CMR 28.07(5)**

---

តាមច្បាប់របស់ **Massachusetts** កំណត់ថា សិស្សពេញវ័យនៅអាយុ(១៨ឆ្នាំ) ។ នៅពេលដែលសិស្សមានអាយុ ១៨ ឆ្នាំ ឱពុកម្តាយ ត្រូវផ្តល់សិទ្ធិអោយកូនធ្វើសេចក្តីសំរេចចិត្តនៅពេលដែលកូនគ្រប់អាយុពេញវ័យ លើកលែងតែមានសេចក្តីសំរេចពី តុលាការជាលាយលក្ខ័អក្សរដើម្បីតែងតាំងអាណាព្យាបាលស្របច្បាប់ក្នុងការធ្វើសេចក្តីសំរេចចិត្ត ឬ កូនរបស់អ្នកបញ្ជាក់ជាលាយលក្ខ័អក្សរថា ចង់ចែករំលែកការធ្វើសេចក្តីសំរេចចិត្តជាមួយអ្នក ឬ ចង់អោយអ្នកធ្វើសេចក្តីសំរេចចិត្តលើកម្មវិធីអប់រំបន្តទៀត ។ ក្នុងករណីនេះ សាលាត្រូវតែធ្វើការពិភាក្សាជាមួយអ្នក និង កូនរបស់អ្នកអំពីផលបះពាល់នៃការផ្ទេរសិទ្ធិ យ៉ាងហោច ណាស់ក្នុងរយះពេលមួយឆ្នាំមុនពេលកូនមានអាយុគ្រប់១៨ឆ្នាំ ។

[2] អ្នកក៏មានសិទ្ធិតាមដានសិស្សរបស់អ្នកក្នុងកម្មវិធីបច្ចុប្បន្នរបស់គេ និងតាមដានកម្មវិធីដែលបានស្នើមុន ការធ្វើតេសន៍ ចូលរបស់សិស្សអ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមមើលឯកសារនៃមន្ទីរអប់រំបឋមសិក្សា និងមធ្យមសិក្សា (ESE) «ការតាមដានកម្មវិធីអប់រំដោយមាតាបិតាសិស្ស»។

បើអ្នកជាមាតាបិតារបស់កូនពិការដែលមានអាយុពេញវ័យ អ្នកនិងត្រូវទទួលសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរពីសាលាជាបន្ត ហើយអ្នកនឹងបន្តការពិនិត្យមើលលើកំណត់ហេតុសិក្សាកូនរបស់អ្នកបានទោះបីកូននោះធ្វើការសំរេចចិត្តលើការសិក្សាដោយខ្លួនឯងក៏ដោយ។

## ២.៣ តើអ្នកតំណាងមាតាបិតាក្នុងការអប់រំផ្តល់ការយល់ព្រមនៅពេលណា?

**34CFR§300.519 (g))**

**603 CMR 28.07(7)**

ប្រសិនបើកូនស្ថិតនៅក្រោមការឃុំឃាំងរបស់មន្ទីរកិច្ចការសង្គម ឬ គេមិនអាចរកឱពុកម្តាយ ឬ អាណាព្យាបាលរបស់សិស្ស ឃើញ ឬ សិទ្ធិអំណាចមេបាត្រូវបញ្ចប់ ESS មានការទទួលខុសត្រូវរកមនុស្សពេញវ័យមួយនាក់ដែលមិនមានទំនាស់ ផលប្រយោជន៍ដើម្បីអោយធ្វើសេចក្តីសំរេចចិត្តលើការអប់រំពិសេសជំនួសសិស្ស។ អ្នកធ្វើសេចក្តីសំរេចចិត្តនោះហៅថា តំណាងមាតាបិតាក្នុងការអប់រំ ។ ESS  ត្រូវកំណត់ ថាតើការជ្រើសតាំងតំណាងមាតាបិតាអោយសិស្ស ជាការចាំបាច់ ឬ មិនចាំបាច់ ។ ប្រសិនបើចាំបាច់ ត្រូវតែជ្រើសសើ  តំណាងមាតាបិតាក្នុងការអប់រំមានសិទ្ធិ និង ទទួលខុសត្រូវក្នុងបញ្ហាសិក្សា របស់សិស្ស តែប៉ណ្ណោះ ។

## ២.៤ តើខ្ញុំដកការអនុញ្ញាតដោយរបៀបណា?

**34 CFR §300.300(B)(4) and 300.9**

ប្រសិនបើអ្នកបានផ្តល់ការអនុញ្ញាតក្នុងការទទួលសេវាកាលពីមុន ហើយឥឡូវនេះអ្នកចង់បញ្ឈប់ការអនុញ្ញាត និងដកហូតសេវាពីសិស្សរបស់អ្នកវិញ អ្នកត្រូវតែធ្វើការបញ្ឈប់ និងដកហូតជាលាយលក្ខណ៍អក្សរ។ អ្នកប្រហែលជាអាចដកការអនុញ្ញាត របស់អ្នកចំពោះគ្រប់ការអប់រំពិសេស និងសេវាពាក់ព័ន្ធ ចំពោះសេវាជាក់លាក់ ឬចំពោះការធ្វើតេសន៍ ចូលរៀន។ នៅពេល ដែលតំបន់សាលាបានទទួលលិខិតរបស់អ្នកតំបន់សាលានឹងផ្ញើលិខិតជូនដំណឹង អំពីការចាប់ផ្តើមផ្លាស់ប្តូរក្នុងការធ្វើតេសន៍ ចូលរៀន និងសេវាអប់រំដែលឆ្លើយតប ការបញ្ឈប់ ការអនុញ្ញាតរបស់អ្នក។ នៅពេលដែលអ្នកដកយកការអនុញ្ញាតរបស់អ្នកចំពោះការអប់រំពិសេស និងសេវាពាក់ព័ន្ធរបស់អ្នក តំបន់សាលានឹងមិនតម្រូវឲ្យសិស្សរបស់អ្នកធ្វើការអប់រំសាធារណៈដោយឥតគិតថ្លៃ និងសមរម្យតាមសមត្ថភាព (FAPE) ឬមានការប្រជុំកម្មវិធីសិក្សាប្រចាំខ្លួន(IEP) ឬអភិវឌ្ឍកម្មវិធីសិក្សាប្រចាំខ្លួន ឡើយ។ តំបន់សាលាមិនតម្រូវឲ្យធ្វើការផ្លាស់ប្តូរកែតម្រូវកំណត់ត្រាសិស្សរបស់អ្នកដើម្បីដកយកឯកសារទាក់ទងនឹងសេវាអប់រំពិសេសជាលិទ្ធផលនៃការបញ្ឈប់ការអនុញ្ញាតរបស់អ្នកទេ។

## ៣. តើដូចម្តេចដែលហៅថាការវាយតំលៃលើការអប់រំដោយឯករាជ

**34CFR§300.502 AND 603 CMR 28.04(5)**

ការវាយតំលៃលើការអប់រំដោយឯករាជ (IEE)
គឺជាការវាយតំលៃធ្វើឡើងដោយអ្នកត្រួតពិនិត្យដែលមានសមត្ថភាពខ្ពស់ហើយ
មិនបំរើការក្នុងសាលារៀនថ្នាក់ស្រុកនេះទេ អ្នកវាយតំលៃមានភារៈទទួលការងារខាងផ្នែកអប់រំសិស្ស។

អ្នកមានសិទ្ធិស្នើរសុំកម្មវិធី IEE សំរាប់កូនរបស់អ្នកដោយចំណាយថវិការសាធារណ:
ប្រសិនបើអ្នកមិនយល់ស្របជាមួយការវាយតំលៃរៀបចំដោយសាលា ។ ប្រសិនបើអ្នកស្នើរសុំ IEE
សាលាត្រូវផ្តល់ពត៌មានជូនអ្នកអំពីកន្លែងដែលស្វែងរកសេវាកម្មវាយតំលៃនោះទៀតផង និង
ពត៌មានដែលរដ្ឋត្រូវការសំរាប់ការវាយតំលៃនោះទៀតផង ។

## ៣.១ តើការវាយតំលៃការអប់រំឯករាជត្រូវចំណាយថវិការសាធារណ:ធ្វើនៅពេលណា?

នៅក្នុង Massachusetts, តាមច្បាប់ អ្នកត្រូវទទួលការវាយតំលៃដោយឯករាជស្ថិតក្រោមការចំណាយ
ថវិការសាធារណ:ទាំងអស់ ឬជាផ្នែកណាមួយ
ប្រសិនបើចំណូលរបស់អ្នកស្ថិតនៅក្នុងលក្ខខ័ណ្ឌដែលមានកំណត់ ។ ចំពោះសិស្សដែលទទួលអាហារ
ដោយឥតគិតថ្លៃ ឬ ដោយបង់ថ្លៃបន្តិចបន្តួច
គឺមានសិទ្ធិទទួលការវាយតំលៃដោយចំណាយលើថវិការសាធារណ: ។
សិស្សផ្សេងទៀតដែលទទួលការវាយតំលៃដោយចំណាយថវិការសាធារណ:មួយចំណែកត្រូវបង់តាមតំលៃ
មានកំណត់ក្នុងតារាង ។
ការចែករំលែកពត៌មានអំពីហិរញ្ញវត្ថុផ្ទាល់ខ្លួនជាមួយសាលារៀនត្រូវធ្វើឡើយដោយស្មគ្រ័ចិត្ត ។
ប្រសិនបើអ្នក
ធ្វើការចែករំលែកពត៌មានហិរញ្ញវត្ថុនោះសាលានិងត្រូវជូនដំណឹងលាយល័ក្ខអក្សរទៅអ្នកវិញជាបន្ទាន់
ដោយបញ្ជាក់ថា តើការវាយតំលៃនោះត្រូវចំណាយថវិការសាធារណ:ទាំងអស់ ឬ ត្រូវចំណាយមួយចំណែក
ហើយការបង់ថ្លៃលើការវាយតំលៃត្រូវធ្វើតាមចំណែកនោះ ។
អ្នកមានសិទ្ធិទទួលការវាយតំលៃដោយចំណាយថវិកាសាធារណ:តាមការកំណត់ប្រាក់ចំណូលរបស់
អ្នកក្នុងកំឡុងពេល១៦ ខែ គិតចាប់ ពីថ្ងៃដែល សាលារៀនបានរៀប ចំការវាយតំលៃ ហើយ
អ្នកមិនយល់ព្រម។

ប្រសិនបើចំណូលរបស់អ្នកមិនដូចការកំណត់
ឬសំរេចមិនផ្តល់ពត៌មានហិរញ្ញវត្ថុទេសាលារៀននឹងពិចារណាទៅលើសំណើរ
សុំអោយមានការវាយតំលៃដោយចំណាយថវិការសាធារណ:តាមច្បាប់សហពន្ធ័ ។ ក្នុងរយ:ពេល៥ថ្ងៃ
សាលារៀនថ្នាក់ស្រុក នឹងសំរេចអោយមានការវាយតំលៃដោយចំណាយថវិការសាធារណ: ឬ
ត្រូវស្នើរសុំសវនាការដែលនឹងប្រព្រឹត្តនៅឯការិយាល័យតវ៉ាខាងផ្នែកអប់រំពិសេស (Bureau of Special

Education Appeals –BSEA) ដើម្បីបញ្ជាក់ថាការវាយតំលៃនោះពិតជាសមរម្យនិងត្រឹមត្រូវ ។ ពត៌មានបន្ថែមស្តីអំពីការវាយតំលៃនេះមាននៅក្នុង ESE Administrative Advisories 2004-1 និង 2001-3 ដែលមាននៅតាមបណ្ណាសាលារៀនក្នុងតំបន់ដែលអ្នករស់នៅ និងនៅតាមគេហទំព័រ http//www.doe.mass.edu/advisories/?sectiion=admin។

អ្នកមានសិទ្ធិអោយគេធ្វើការវាយតំលៃទៅលើកូនរបស់អ្នកដោយចំណាយថវិកាសាធារណៈតែមួយដងគត់ នៅពេលដែលសាលារៀបចំការវាយតំលៃម្តងៗ ។ អ្នកក៏អាចអោយគេវាយតំលៃលើកូនរបស់អ្នកដោយឯករាជដោយចំណាយថវិកាផ្ទាល់ខ្លួនបានដែរ ។

## ៣.២ សាលារៀនថ្នាក់ស្រុកត្រូវពិចារណាលទ្ធផលនៃការវាយតំលៃក្នុងរយះពេល១០ថ្ងៃ

ប្រសិនបើអ្នកទទួលបានការវាយតំលៃកូនរបស់អ្នកដោយចំណាយថវិការដ្ឋ ឬក៏ចំណាយថវិកាផ្ទាល់ខ្លួនមួយចំណែកខ្លះ ជាមួយសាលាដើម្បីធ្វើការវាយតំលៃកូនរបស់អ្នក សាលានឹងត្រូវរៀបចំការប្រជុំមួយក្នុងរយះពេល១០ថ្ងៃ គិតតែថ្ងៃធ្វើការ បន្ទាប់ពីអ្នកទទួលពត៌មាននៃការវាយតំលៃនោះ ។ ក្រុមការងារ នឹងពិចារណាទៅលើលទ្ធផលនៃការវាយតំលៃ ហើយ កំណត់ថាតើត្រូវធ្វើការផ្លាស់ ប្តូរអ្វីខ្លះនៅក្នុង កម្មវិធីសិក្សាលក្ខណៈឯកជនសំរាប់កូនអ្នក ។

## ៤. តើអ្នកអាចមើលកំណត់ត្រាសិស្សបាននៅពេលណាខ្លះ?
**34 CFR 300.611 AND 603 CMR 23.00**

ក្នុងកំណត់ត្រារបស់សិស្សមានពត៌មានដូចជា មុខវិជ្ជាសិក្សា កំណត់ហេតុសាលាបណ្តោះអាសន្ន សុខភាព ការប្រឡង ការវាយតំលៃ វិន័យ និង កំណត់ហេតុផ្សេងទៀត ដែលទាក់ទងទៅនឹងសិទ្ធិទទួល បានការអប់រំពិសេស ឬ កម្មវិធីអ្វីមួយ[3]។ ព័ត៌មានផ្ទាល់ខ្លួនដែលអាចកំណត់បានរបស់សិស្សអ្នកជាការសម្ងាត់ និងប្រហែលជាមិនអាចបង្ហាញដល់នរណាម្នាក់ផ្សេងទៀតក្រៅពីគ្រូបង្រៀន និងមន្ត្រីអប់រំដោយគ្មានការអនុញ្ញាតពីអ្នកឡើយ។

អ្នក និង កូនរបស់អ្នក (ប្រសិនបើមានអាយុ១៤ ឆ្នាំ ឬ ១៤ ឆ្នាំឡើងទៅ) មានសិទ្ធិមើលកំណត់ត្រាសិស្ស ខ្លះៗ ឬ មើលបាន ទាំងអស់ក្នុងរយះពេល ១០ថ្ងៃ បន្ទាប់ពីថ្ងៃដែលស្នើរសុំ ឬ មុនពេលកិច្ចប្រជុំកម្មវិធីសិក្សា

[3] ប្រសិនបើមាតាបិតាសិស្សដកការអនុញ្ញាតរបស់ពួកគេពីសេវាអប់រំពិសេសបន្ទាប់ពីសេវាប្រភេទនេះត្រូវបានចាប់ផ្តើមផ្តល់ តំបន់សាលាមិនតម្រូវឲ្យកែប្រែកំណត់ត្រារបស់សិស្សដើម្បីដកឯកសារយោងនៃសេវាអប់រំពិសេសទេ។

ឬសវនាការយុត្តិធម៌[4]។ អ្នកអាចទទួលពត៌មាន កំណត់ហេតុសិស្សមួយច្បាប់បន្ទាប់ពីអ្នក ស្នើរសុំ ។
**កំណត់ចំពោះតម្លៃនៃការផលិតឡើងវិញ។ អ្នកប្រហែលជាមិនត្រូវបង់ថ្លៃសេវាពាក់ព័ន្ធនឹងការស្វែងរក និងទទួលយកកំណត់ត្រារបស់អ្នកទេ។**

លើសពីនេះទៅទៀត អ្នកអាចជួបជាមួយបុគ្គលិកសាលាដែលមានលក្ខណៈសម្បត្តិវិជ្ជាជីវៈគ្រប់គ្រាន់ ដើម្បីជួយពន្យល់ កំណត់ហេតុសិស្ស ។ អ្នកអាចសុំអោយអ្នកតំណាងដូចជា ( អ្នកតស៊ូមតិ ទីប្រឹក្សា ឬ មេធាវី ) ត្រួតពិនិត្យសើរើមើល និង ធ្វើ ការបកស្រាយកំណត់ហេតុសិស្ស ប្រសិនបើអ្នកយល់ព្រមជាលាយលក្ខ័អក្សរ។ រាល់សិទ្ធិដែលទាក់ទងទៅនឹងកំណត់ហេតុសិស្សមានចែងនៅក្នុងបទបញ្ជាកំណត់ហេតុសិស្ស Massachusetts 603 C.M.R 23.00 ។ បទបញ្ជាទាំងនោះក៏មាន នៅក្នុងគេហទំពរ៍: http//.doe.mass.edu/lawsregs /603cmr23.html ។ ឬ អាចស្នើរសុំបទបញ្ជានេះពី សាលារៀន ឬ ពី ESE។

ជាទូទៅមានតែឪពុកម្តាយ សិស្ស និង បុគ្គលិកសាលា មន្ត្រីអប់រំរបស់រដ្ឋ និង សហព័ន្ធទេដែលត្រូវបានអនុញ្ញាតអោយ មើលកំណត់ហេតុសិស្សដោយមិនចាំបាច់មានការយល់ព្រមជាលាយលក្ខ័អក្សរពីឪពុកម្តាយ ឬ កូនពេញវ័យ ។ សាលារៀន អាចតំរូវអោយ ផ្តល់ពត៌មាន ជូនមន្ត្រីរដ្ឋ ឬ សហព័ន្ធតាមការសំរេចរបស់តុលាការ ឬ ដើម្បីឆ្លើយតបទៅនិងបញ្ហាសុខភាព សុវត្ថិភាព ឬ ការអនុវត្តច្បាប់ ។ ពត៌មាន និង កំណត់ហេតុសិស្សមាននៅក្នុងគេហទំព័រ: http//www.doe.mass.edu/lawsregs/advisory/cmr23ganda.htm.

៥ តើឪពុកម្តាយនិងសាលារៀនត្រូវដោះស្រាយជំលោះដោយវិធីណា?

**34 CFR 300.151,300.506-300.518 AND 603 CMR 28.08**

---

ច្បាប់របស់រដ្ឋ និង សហព័ន្ធត្រូវផ្តល់ឱកាសដល់ឪពុកម្តាយដើម្បីអោយចូលរួមនៅក្នុងការរៀបចំផែនការអប់រំសំរាប់សិស្សពិការ ។ ប្រសិនបើឪពុកម្តាយ និង សាលារៀនមិនយល់ព្រមអំពីការផ្លាស់ប្តូរដែល ទាក់ទងទៅ និងសិទ្ធិទទួលសេវាកម្ម ការវាយតំលៃ ឬ ការផ្លាស់ប្តូរកន្លែងសិក្សារបស់សិស្សពិការ ឬ សេវាកម្ម FAPE

4 សាលារៀនថ្នាក់ស្រុកកំណត់អំពីការពិនិត្យមើលកំណត់ហេតុរបស់សិស្សប្រសិនបើសាលាបានទទួលលិខិតផ្លូវច្បាប់នានាដូចជាដីការការពារ ការលែងលះ ឬ ឃុំឃាំងដែលហាមមិនអោយបុគ្គលពាក់ពន្ធ័មើលពត៌មានរបស់សិស្ស។

ដែលត្រូវគេផ្តល់ដល់សិស្សពិការច្បាប់បើក
ផ្លូវអោយធ្វើការដោះស្រាយចំពោះបញ្ហាមិនចុះសំរុងនឹងគ្នាដោយមធ្យោបាយច្រើនយ៉ាង។

កូនរបស់អ្នកត្រូវស្ថិតនៅក្នុងកម្មវិធីសិក្សា ឬ កន្លែងសិក្សាបច្ចុប្បន្នសិន ក្នុងកំឡុងពេលមានជំលោះកើតឡើងទាក់ទងទៅនឹង កន្លែងអោយចូលសិក្សា ឬ សេវាកម្មផ្សេងៗ លើកលែងតែ អ្នកនិងសាលារៀនយល់ព្រម ឬផ្លាស់ប្តូរកន្លែងចូលរៀនធ្វើឡើងដោយសារតែការដាក់ពិន័យ។ ខាងក្រោមនេះជាជំរើសសំរាប់អ្នក និង សាលារៀនអាចដោះស្រាយជំលោះបាន។

## ៥.១ ចំណាប់អារម្មណ៍របស់មន្ត្រីសាធារណៈមូលដ្ឋានទៅលើការដោះស្រាយជំលោះ

---

ដំណាក់កាលដំបូងដើម្បីធ្វើការដោះស្រាយជំលោះ អ្នកអាចទាក់ទងនាយកសាលា ប្រធានរដ្ឋបាលរបស់កម្មវិធីសិក្សា ពិសេស ឬបុគ្គលិកថ្នាក់លើដើម្បីអោយជួយអ្នក។ វាជាការល្អប្រសិនបើអ្នកសរសេរជាលាយលក្ខ័អក្សរពន្យល់ពីមូលហេតុ ណាមួយដែលអ្នកព្រួយបារម្មណ៍

## ៥.២ ការប្រើប្រាស់ប្រពន្ធ័ដោះស្រាយជំលោះរបស់ **ESE**

---

បើអ្នកគិតថាអ្នកត្រូវការជំនួយពីខាងក្រៅសាលារៀន អ្នកអាចទាក់ទង ESE-ការិយាល័យនៃកម្មវិធីសេវាកម្មធានាគុណភាព (PQA) តាមទូរសព្ទ័លេខ ៧៨១-៣៣៨-៣៧០០ ដើម្បីប្រើប្រាស់ ប្រព័ន្ធដោះស្រាយជំលោះរបស់ រដ្ឋដែលមាននៅក្នុង គេហទំព័រ http://www.doe.mass.edu/edu/pqa/prs/ អ្នកអាចដាក់ពាក្យបណ្តឹងទៅ PQA ប្រឆាំងនឹងការរំលោភច្បាប់ របស់រដ្ឋនិងសហាពន្ធ័ ឬ ដើម្បីទទួលជំនួយពី បុគ្គលិករបស់ PQA អោយជួយដោះស្រាយបញ្ហាក្រៅផ្លូវការ ។ ប្រសិនបើ អ្នកចង់បានការស៊ើបអង្កេត ជាផ្លូវការពី PQA អ្នកត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខ័អក្សរ ។ បុគ្គលិករបស់ PQA និង ជួយរៀបចំដាក់ពាក្យបណ្តឹង ។ បណ្តឹងលាយលក្ខ័អក្សររបស់អ្នកត្រូវមានរួមដូចជា ៖ សរសេរបញ្ជាក់អំពីការ ព្រួយបារម្មណ៍ គោលបំណងនៃដំណោះ ស្រាយការព្រួយបារម្មណ៍របស់អ្នកដោះស្រាយសកម្មភាពរបស់សាលាដែលអ្នកមានជំនឿថាអាចដោះស្រាយការព្រួយបារម្មណ៍របស់អ្នក លើសពីនេះទៀតពាក្យបណ្តឹងត្រូវមាន ហត្ថលេខានិងពត៌មានសំរាប់ទំនាក់ទំនង ។ ប្រសិនបើពាក្យបណ្តឹងអំពីបញ្ហាទាក់ទងទៅសិស្សណាម្នាក់ អ្នកត្រូវប្រាប់ឈ្មោះរបស់សិស្ស និងអាសយដ្ឋាន និងឈ្មោះសាលារៀន ។ បញ្ហាដែលអ្នកត្រូវប្តឹងមិនត្រូវមានរយៈពេលអោយលើសពី១ឆ្នាំ គិតចាប់រហូតដល់ថ្ងៃ PQA ទទួល ពាក្យបណ្តឹងនោះ ។ ប្រសិនបើអ្នកសំរេចប្តឹងតាមប្រព័ន្ធដោះស្រាយជំលោះជាផ្លូវការរបស់ PQA អ្នកត្រូវផ្ញើពាក្យបណ្តឹងជាលាយល័ក្ខអក្សរមួយច្បាប់ជូនទៅសាលារៀនថ្នាក់ស្រុកដែលជាកម្មវត្ថុនៃបណ្តឹង ។ PQA និងធ្វើការដោះស្រាយបណ្តឹង របស់អ្នកក្នុងរយៈពេល ៦០ ថ្ងៃ ហើយ PQA និងផ្ញើលទ្ធផល ព្រមទាំងសេចក្តីសំរេចជូនអ្នកមួយច្បាប់។

ទោះបីជាដាក់ពាក្យបណ្តឹងទៅ PQA អ្នកនៅតែអាចប្រើប្រាស់មធ្យោបាយផ្សេងទៀតដើម្បីដោះស្រាយជំលោះ ដូចជា ការពិភាក្សាជាមួយសាលារៀនថ្នាក់មូលដ្ឋាន ការសម្របសម្រួល ឬ សវនាការដោយយុត្តិធម៌នៅការិយាល័យបណ្តឹងតវ៉ាផ្នែកអប់រំពិសេស (មានសេចក្តីពិស្តារ ខាងក្រោម) ដើម្បីដោះស្រាយពាក្យបណ្តឹង[5] របស់អ្នក ។ ប្រសិនបើអ្នកជ្រើសរើសយកសវនាការដោយយុត្តិធម៌ ពាក្យបណ្តឹងដាក់តាមរយះប្រព័ន្ធដោះស្រាយជំលោះនិងត្រូវផ្អាកមួយរយះរហូតដល់ពេលសវនាការយុត្តិធម៌ ត្រូវបានដោះស្រាយចប់ជាមុនសិន ។

## ៥.៣ ស្នើរសុំតែងតាំងអ្នកសម្របសម្រួលអព្យាក្រិត

---

ការសម្របសម្រួល[6] គឺ ជាសេវាកម្មមួយបំពេញការងារដោយអ្នកសម្របសម្រួល ឯករាជ មានជំនាញច្បាប់អប់រំពិសេស និង ជាអ្នកមានជំនាញចរចារ ។ ការសម្របសម្រួលអាចប្រព្រឹត្តិទៅ ក្នុងខណ: ពេលដែល ឪពុកម្តាយ និង សាលារៀន មិនចុះសំរុងនឹងគ្នាអំពីបញ្ហាអប់រំពិសេស ទោះបីជាពាក្យបណ្តឹងនោះបានដាក់តាមរយះប្រពន្ធ័ដោះស្រាយជំលោះរបស់ PQA រួចហើយក៍ដោយ ។ អ្នកសម្រប សម្រួល ជួយភាគីខាងឪពុកម្តាយ និង សាលាអោយមានការពិភាក្សាអំពីការមិនចុះសំរុង និង ជួយអោយឆ្ពោះទៅរកដំណោះស្រាយដែលភាគីទាំងពីរព្រមព្រៀងទទួលយក។

ការជជែកដេញដោលនៅពេលសម្របសម្រួលនោះនឹងត្រូវរក្សាជាការសំងាត់ – ហើយភាគីទាំងពីរមិនយកការជជែកគ្នានេះ ទៅប្រើប្រាស់នៅថ្ងៃក្រោយទៀតបានទេ ទោះបីជំលោះនោះក្លាយជាប្រធានបទដែលត្រូវដោះស្រាយតាមសវនាកាផ្លូវការ ឬ តាមនិតិវិធីតុលាការក៍ដោយ។ នៅពេលដែលមានការព្រមព្រៀងគ្នាសេចក្តីសំរេច នោះត្រូវធ្វើលាយលក្ខ័អក្សរដែលមានចុះហត្ថលេខាពីភាគីទាំងពីរ និង ត្រូវអនុវត្តដោយតុលាការ។

ដើម្បីធ្វើការសម្របសម្រួលសូមទំនាក់ទំនង BSEA តាមលេខ ៧៨១ ៣៣៨ ៦៤៤៣ ។ អ្នកសម្របសម្រួលនិងកំណត់កាល បរិច្ឆេទប្រជុំជាមួយអ្នក និងសាលារៀនក្នុងរយះពេល៣០ថ្ងៃបន្ទាប់ពីទទួលពាក្យបណ្តឹងសម្របសម្រួល ។ ការសម្របសម្រួល ប្រព្រឹត្តិទៅតាមពេលវេលានិងទីកន្លែងដ៍សមគួរ។ ការចូលរួមត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ។ ដូច្នេះភាគីឪពុកម្តាយ និង សាលារៀនត្រូវយល់ព្រមចូលរួមក្នុងការសម្របសម្រួលនេះ។ មិនត្រូវចាំបាច់បង់ថ្លៃសេវាកម្មនេះទេ។ ពត៏មានបន្ថែមអំពីការសម្របសម្រួល អាចទំនាក់ទំនងទៅ **BSEA**

---

[5] សំរាប់ធ្វើការប្រៀបធៀបមធ្យោបាយដោះស្រាយតាមប្រពន្ធ័ដោះស្រាយជំលោះ ទៅនឹងការដោះស្រាយពាក្យបណ្តឹងតាមដំណើករយុត្តិធម៌ សូមមើលតាម: ហាតតផ:,,ដៀៀ។មាសស។ដេ៉,សផដេ,ដៀចស។ហាតមល

[6] ការពិពត៏នាអំពីដំណើរការសម្របសម្រួលមាននៅក្នុងគេហទំព័រ: http//www.doe.mass.edu/bsea/mediation.html

តាមលេខ ៧៨១ ៣៣៨ ៦៤០០ និង មានចុះផ្សាយតាមរយះសំនួរចំលើយអំពីការសម្របសម្រួល[7] ◌̈ និង ◌̈ ការពន្យល់អំពីការ សម្របសម្រួល[8] ◌̈ ។

## ៥.៤ ការស្នើរសុំសវនាការយុត្តិធម៌ និង ចូលរួមក្នុងការប្រជុំដោះស្រាយជំលោះ

---

ប្រសិនបើ អ្នក និង សាលារៀនមិនអាចធ្វើការដោះស្រាយភាពមិនចុះសំរុងនឹងគ្នាបានទេ អ្នកមានសិទ្ធិស្នើសុំអោយមន្ត្រី សវនាការអព្យាក្រឹត ស្តាប់បញ្ហានៃភាគីជំលោះទាំងពីរ ការសួរដេញដោលពិនិត្យមើលភស្តុតាង និងធ្វើសេចក្តីសំរេច ។ សវនាការនេះត្រូវរៀបចំដោយ BSEA ហើយមានឈ្មោះថា សវនាការយុត្តិធម៌ ។ មន្ត្រីសវនាការរបស់ BSEA តែងតែទទួល ការហ្វឹកហ្វឺនច្បាប់អប់រំពិសេស ហើយមិនមានទំនាក់ទំនងផ្ទាល់ខ្លួន ឬ វិជ្ជាជីវៈ ជាមួយភាគីណាមួយដែលពាក់ព័ន្ធនឹងភាព មិនចុះសំរុងគ្នានេះទេ។

សវនាការយុត្តិធម៌នេះនឹងពិចារណាជំលោះទៅលើកត្តានានាដូចជា សិទ្ធិទទួលបាន ការវាយតំលៃ IEPS និងកន្លែងចូលសិក្សា ដែលមានរួមទាំងលទ្ធផលនៃដាក់ពិន័យ FAPE និង ការផ្តល់កម្មវិធីអប់រំពិសេស ព្រមទាំងនិតិវិធីការពារដែលមានចែងក្នុង ច្បាប់សហព័ន្ធ និងច្បាប់រដ្ឋសំរាប់ការពារសិស្សពិការ។ អ្នកត្រូវដាក់ពាក្យស្នើរសុំសវនាការក្នុងរយះពេលពីរបន្ទាប់ពីអ្នកបានដឹងហេតុការណ៍ ឬ ចាប់ពីពេលដែលអ្នកគួរតែដឹង[9] អំពី ព្រឹត្តិការណ៍ដែលបណ្តាលអោយមានជំលោះនេះ។ រយះពេលនេះអាចពន្យាបានយូរបន្តិច ប្រសិនបើអ្នកអាចបង្ហាញថា មានគេរាំងអ្នកមិនអោយដាក់ពាក្យបណ្តឹងសុំសវនាការ ពីព្រោះសាលារៀនមានការបកស្រាយខុស – ដោះស្រាយបណ្តឹង រួចហើយ ឬ បង្ហាញថាសាលារៀនបានលាក់ទុកពត៌មានដែលសាលាបានទទួលពីអ្នក។

អ្នក ឬសាលារៀនអាចដាក់ពាក្យបណ្តឹងស្នើរសុំ[10]សវនាការដោយយុត្តិធម៌ជាលាយល័ក្ខអក្សរ ហើយផ្ញើពាក្យបណ្តឹង១ច្បាប់ មកអោយ **BSEA** ដើម្បីអោយទទួលបានសវនាការដោយយុត្តិធម៌ ។ **BSEA** បានបង្កើតបែបបទគំរូស្នើរសុំសវនាការ[11] សំរាប់ ប្រើប្រាស់ ឬ អ្នកអាចសរសេរពាក្យបណ្តឹងដោយខ្លួនឯងដោយមិនបាច់ប្រើបែបបទដែលមានស្រាប់នោះទេ។ ក៏ប៉ុន្តែអ្នកត្រូវ ធានាថាក្នុងពាក្យនោះត្រូវមានឈ្មោះសិស្ស អាស្រ័យដ្ឋាន (ឬពត៌មានសំរាប់ទំនាក់ទំនង ប្រសិនបើសិស្សមិនមាន លំនៅឋាន ប្រាដក) ឈ្មោះសាលារៀនសរសេរបញ្ជាក់ពីបញ្ហាមានរួមទាំងអង្គហេតុជាក់លាក់ដែលទាក់ទងទៅនឹងបញ្ហា និង ដំណោះស្រាយដែលចង់បាន ។ សូមញ្ជាក់ថាសវនាការផ្តោទៅលើបញ្ហាដែលមាននៅក្នុងពាក្យបណ្តឹងនោះទេ។

---

[7] http://www.doe.mass.edu/bsea/mediation.html?section=fag
[8] http://www.doe.mass.edu/bsea/forms/m_brochure.doc
[9] ឃ្លាដែលថា គួរតែដឹង ◌̈ រលឹកអ្នកថា អ្នកមានការទទួលខុសត្រូវក្នុងការស្វែងយល់ដឹងអំពីកម្មវិធីសិក្សារបស់កូនអ្នក ។
[10] ពត៌មានស្តីអំពីសវនាការដោយយុត្តិធម៌មាននៅក្នុងគេហទំព័រ: http://www.doe.mass.edu/bsea/process.html?section=1
[11] http://www.doe.mass.edu/bsea/forms/hearing.doc

អ្នកត្រូវផ្ញើពាក្យស្នើរសុំសវនាការនោះទៅសាលារៀន (ភាគីដែលពាក់ព័ន្ធក្នុងបណ្តឹង) ហើយផ្ញើមួយច្បាប់ទៀតទៅ BSEA ។ ប្រសិនបើពាក្យបណ្តឹងមិនផ្តល់ពត៌មានគ្រប់គ្រាន់ទេ ភាគីជំទាស់អាចធ្វើការជំទាស់ក្នុងរយៈពេល១៥ថ្ងៃ ។ ក្នុងរយៈពេល៥ ថ្ងៃ ចាប់ពីថ្ងៃតវ៉ា BSEA នឹងសំរេចថាពាក្យបណ្តឹងនោះមានពត៌មានគ្រប់គ្រាន់ ឬ មិនគ្រប់គ្រាន់ ។ បើមានការចាំបាច់ ភាគីពាក់ព័ន្ធអាចសរសេរពត៌មានបន្ថែមទៀតទៅក្នុងពាក្យបណ្តឹង ប្រសិនបើភាគីជំទាស់យល់ព្រម ឬ មន្ត្រីសវនាការយល់ព្រម ។ ប្រសិនបើ ពត៌មានត្រូវបន្ថែមនៅពេលអនាគតពេលវេលាសវនាការត្រូវលើទៅថ្ងៃក្រោយ។

ប្រសិនបើ មិនមានការជំទាស់ទៅនឹងការខ្វះខាតពត៌មានក្នុងពាក្យបណ្តឹងទេ សវនាការអាចបន្តទៅមុខទៀតបាន។ ប្រសិនបើ សាលា មិនទាន់ផ្ញើសេចក្តីជូនដំណឹងមកអ្នកអំពីបញ្ហាដែលអ្នកប្តឹងជាលាយល័ក្ខអក្សរទេ ក្នុងរយៈពេល ១០ថ្ងៃ គិតចាប់ពីថ្ងៃ ទទួលពាក្យបណ្តឹង ស្នើរសុំអោយមានសវនាការ សាលាត្រូវតែធ្វើការឆ្លើយតបមកអ្នកជាលាយល័ក្ខអក្សរ ។

សូមកត់សំគាល់ថា: ប្រសិនបើសាលារៀនថ្នាក់ស្រុក បានស្នើរសុំសវនាការដោយយុត្តិធម៌ ឪពុកម្តាយ ត្រូវឆ្លើយតបក្នុងរយៈ ពេល១០ ថ្ងៃបន្ទាប់ពីទទួលលិខិតជូនដំណឹងនោះ ហើយការឆ្លើយតបត្រូវ បញ្ជាក់អំពីបញ្ហាដែលសាលារៀនបានលើកឡើង។

បន្ទាប់ពីអ្នកដាក់ពាក្យស្នើរសុំសវនាការដោយយុត្តិធម៌ សាលារៀនត្រូវឆ្លើយតបមកអ្នកវិញក្នុងរយៈពេល៣០ថ្ងៃ ដើម្បីធ្វើ ការដោះស្រាយភាពមិន ចុះសំរុងគ្នាអោយបានមុនពេលដំណើរការសវនាការចាប់ផ្តើម[12]។

សាលារៀនថ្នាក់ស្រុកតំរូវអោយរៀបចំការប្រជុំដោះស្រាយក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីថ្ងៃទទួលពាក្យបណ្តឹង[13] សាលារៀន នឹងត្រូវពិភាក្សាជា មួយអ្នកថាតើសមាជិកក្រុម IEP ណាម្នាក់នឹងត្រូវចូលរួមប្រជុំ ។ បុគ្គលិកសាលារៀនដែលធ្លាប់ សំរេចចិត្តអំពីកម្មវិធីអប់រំ របស់សិស្សត្រូវតែចូលរួមក្នុងការប្រជុំនេះកុំបីអាក់ខាន ។ មេធាវី របស់សាលារៀនមិនអាចចូលរួម ប្រជុំទេ ប្រសិនបើមេធាវីអ្នកនឹងចូលរួមក្នុងអង្គប្រជុំនោះ។

អ្នកត្រូវតែចូលរួមប្រជុំដោះស្រាយបញ្ហា លើកលែងតែអ្នក និងសាលារៀនយល់ព្រមគ្នាជាលាយល័ក្ខអក្សរថាមិនចាំបាច់ រៀបចំការប្រជុំ ឬក៏អ្នក

[12] ប្រសិនបើអ្នក និង សាលារៀនយល់ស្របតាមការសម្របសម្រួល អ្នកនឹងអាចបន្តការសម្របសម្រួលក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពី៣០ផុតទៅ

[13] មិនមានការប្រជុំដោះស្រាយទេ ប្រសិនសាលារៀនស្នើរសុំអោយមានសវនាការយុត្តិធម៌វិញ

និងសាលារៀនសំរេចយកការសម្របសម្រួលវិញ។ ប្រសិនបើ សាលារៀនមិនអាចអោយអ្នកចូលរួម ប្រជុំបាន សាលារៀននឹង ស្នើសុំអោយមន្ត្រីសវនាការច្រានចោល ពាក្យ បណ្តឹង។

បើអ្នកមានបំណងចង់ចូលរួមប្រជុំ តែសាលារៀនបដិសេធ ឬ ពន្យាពេលនៃការប្រជុំ អស់រយៈពេលជាង១៥ ថ្ងៃគិតចាប់ពី ថ្ងៃទទួលសេចក្តីជូនដំណឹងអំពីសវនាការ
អ្នកអាចសុំអោយមន្ត្រីសវនាការបន្តដំណើរការសវនាការតទៅទៀតបាន។ ប្រសិនបើអ្នកបានចូលរួមប្រជុំ ក៏ប៉ុន្តែសាលាមិនបានដោះស្រាយបណ្តឹងតាមឆន្ទៈរបស់អ្នកក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃ ដាក់ពាក្យបណ្តឹង ដូច្នេះដំណើរការនៃសវនាការត្រូវតែបន្តទៅមុខទៀត។

ដំណើរការដោះស្រាយត្រូវបញ្ចប់នៅពេលដែលព្រឹត្តិការណ៍ណាមួយដូចខាងក្រោមកើតឡើង:

- នៅពេលដែលអ្នក និង
  សាលារៀនយល់ព្រមជាលាយល័ក្ខអក្សរដើម្បីបញ្ចប់អាជ្ញាយុកាលនៃដំណោះ ស្រាយ។
- រយៈពេល៣០ថ្ងៃសំរាប់ដំណោះស្រាយត្រូវបានបញ្ចប់
- បញ្ចប់ការសម្របសម្រួល ឬ
- នៅពេលដែលអ្នក
  និងមន្ត្រីរបស់សាលាចុះហត្ថលេខាលើឯកសារដែលប្រកាសថាភាគីទាំងពីរយល់ព្រមដោះស្រាយ ជំលោះរបស់អ្នក ។ នេះជាកិច្ចព្រមព្រៀងដំណោះស្រាយ
  ហើយនឹងត្រូវអនុវត្តដោយតុលាការសហព័ន្ធ ឬតុលាការ រដ្ឋ។ សូមបញ្ជាក់ថា ប្រសិនបើអ្នក និង សាលារៀន យល់ព្រមគ្នាក្នុងអង្គប្រជុំ អ្នក និង សាលារៀនក៏អាចបដិសេធកិច្ច
  ព្រមព្រៀងដែលអ្នកចុះហត្ថល្លេខាក្នុងរយៈពេល៣ថ្ងៃគិតចាប់ពីថ្ងៃព្រមព្រៀងគ្នា។

## ៥. ៥ ការបង្ហាញភស្តុតាងជូនមន្ត្រីសវនាការអព្យាក្រិតនៅពេលសវនាការ

នៅពេលដែលអ្នកដាក់ពាក្យបណ្តឹង BSEA និងកំណត់ថ្ងៃសវនាការ-ចាត់តាំងមន្ត្រីសវនាការ និងផ្ញើពត៌មានពិស្តារអំពី សវនាការជូនអ្នក និង ព្រមផ្ញើទាំងជូនអ្នកនូវបញ្ជីរឈ្មោះមេធាវីដោយមិនគិតកំរៃ ឬគិតកំរៃតិចតួចសំរាប់អ្នកធ្វើ ការទំនាក់ ទំនងសុំជំនួយ។

ក្នុងកំឡុងពេលសវនាការ អ្នក និង សាលារៀនថ្នាក់ស្រុកនិងត្រូវបង្ហាញភស្តុតាង និង ផ្តល់សក្ខីភាពសាក្សីជូនមន្ត្រីសវនាការ អព្យាក្រឹតដែលអញ្ជើញមកពី BSEA ។ ក្នុងកំឡុងពេលសវនាការ មានរួមទាំងសវនាការលើនិតិវិធីនៃការដាក់វិន័យ ហើយអ្នកអាច:

- អោយមានការអមដំណើរ ផ្តល់យោបល់ ឬ ត្រូវជំណាងដោយមេធាវី ឬ អ្នកតស៊ូមតិ
- អោយកូនរបស់អ្នកមានវត្តមាននៅពេលសវនាការ
- សុំអោយសវនាការជាសាធារណៈ:
- សុំអោយបង្ហាញភស្តុតាងដូចជាឯកសារ និង របាយការណ៍

- ស្នើរសុំ ឬតំរូវអោយចេញដីការកោះហៅសាក្សីអោយចូលរួមក្នុងសវនាការ និង ឆ្លើយសំនួរ
- សុំមើលភស្តុតាងដែលប្រើប្រាស់ពេលសវនាការក្នុង៥ថ្ងៃមុនសវនាការមកដល់ និងស្នើរសុំអោយមន្ត្រីសវនាការ ច្រាន ចោលភស្តុតាងដែលអ្នកមិនបានឃើញ។
- ទទួលបាននូវកំណត់ហេតុ លទ្ធផលអង្គហេតុ និងសេចក្តីសំរេចតាមជំរើស ដូចជាលាយល័ក្ខអក្សរអេឡិចត្រូនិច ដោយឥតគិតកំរៃ។ ដើម្បីទទួលកំណត់ហេតុសវនាការជាលាយល័ក្ខអក្សរ អ្នកត្រូវធ្វើការស្នើរសុំជាលាយល័ក្ខអក្សរ ។

ពត៌មានបន្ថែមស្តីអំពីសវនាការនេះអាចស្នើរសុំពី BSEA តាមទូរសព្ទ័លេខ ៧៨១៣៣៨៦៤០០ និងអាចបើកមើលតាម គេហទំព័រ http://www.doe.mass.edu/bsea/process។

សវនាការប្រព្រឹត្តទៅតាមច្បាប់[14]និតិវិធីរដ្ឋបាល Masssachusetts និង គោលការណ៍សវនាការ BSEA[15]។ មន្ត្រីសវនា ការត្រូវចេញសេចក្តីសំរេចក្នុងរយះពេល ៤៥ថ្ងៃ បន្ទាប់ពីបញ្ចប់នៃអជ្ញាយុកាលនៃជំលោះដូចមានចែងខាងលើ លើកលែងតែ មន្ត្រីសវនាការពន្យាពេលបន្ថែមទៀតតាមការស្នើរសុំពីភាគីណាមួយ។ មន្ត្រីសវនាការផ្ញើជូនសេចក្តីសំរេចមកអ្នក និងទៅ សាលារៀនថ្នាក់ស្រុកមួយច្បាប់ម្នាក់ ។ មន្ត្រីសវនាការ និងសាលារៀនត្រូវគោរពតាមសេចក្តីសំរេចរបស់មន្ត្រីសវនាការ។

សេចក្តីសំរេចរបស់មន្ត្រីសវនាការថាតើកូនរបស់អ្នកមានសិទ្ធិ ឬ មិនមានសិទ្ធិទទួល FAPE ត្រូវផ្អែកលើការរកឃើញសិទ្ធិ ទទួលការអប់រំពិសេសដែលត្រូវបានគេរំលោភ ឬ ត្រូវបញ្ចប់ដោយសាលារៀនមិនអាចបំពេញកាតព្វកិច្ចដល់សិស្ស ដូចមាន ចែងក្នុងច្បាប់អប់រំពិសេស និង បទបញ្ញា ។ ប្រសិនបើអ្នកបានដាក់ពាក្យប្តឹងអំពីការរំលោភនិតិវិធីការអប់រំពិសេស (ដូចជាមិន បានរៀបចំប្រជុំក្រុមអោយបានត្រឹមត្រូវពុំបានរក្សាទុកកំណត់ហេតុអោយបានល្អ និង មិនគោរពពេលវេលា) មន្ត្រីសវនាការ អាចរកឃើញថា សិស្សពិតជាមិនបានទទួល FAPE ប្រសិនបើសាលារៀនមិនគោរពនិតិវិធីដូចជា:

- បះពាល់សិទ្ធិរបស់សិស្ស ក្នុងការទទួល FAPE
- បះពាល់លទ្ធភាពរបស់សិស្សក្នុងការចូលរួមធ្វើសេចក្តីសំរេចអំពីការអប់រំរបស់កូនអ្នក
- មិនអោយសិស្សទទួលបានផលប្រយោជន៍ពីការអប់រំ។

សេចក្តីសំរេចរបស់មន្ត្រីសវនាការជាសេចក្តីសំរេចរបស់ស្ថាប័នចុងក្រោយ ហើយមិនអាចធ្វើការពិចារណាជាថ្មីដោយ BSEA ឬ កែប្រែដោយ ESE បានទេ ។

---

[14] M.G.L.c.30A

[15] http://www.doe.mass.edu/bsea/forms/hearing_rules.doc

សេចក្តីសំរេចរបស់សវនាការត្រូវជាសាធារណៈ[16] ហើយមាននៅក្នុងគេហទំព័រ http://www.doe.mass.edu/bsea/decisions

## ៥.៦ ការជំទាស់សេចក្តីសំរេចទៅតុលាការសហពន្ធ័ និង តុលាការរដ្ឋ

---

ភាគីសាលារៀន ឬ ឱពុកម្តាយដែលមិនយល់ព្រមទៅនឹងសេចក្តីសំរេចរបស់មន្ត្រីសវនាការ ពួកគេអាចធ្វើបណ្តឹងសើរើលើ សេចក្តីសំរេចនោះតាមតុលាការរដ្ឋ ឬសហពន្ធ័ ។ បណ្តឹងសើរើនោះត្រូវដាក់ក្នុងរយៈពេល៩០ថ្ងៃបន្ទាប់ពីចេញសេចក្តីសំរេច។

## ៥.៧ តំលៃរបស់មេធាវី

**34CFR§300.517**

---

ភាគីនីមួយៗទទួលខុសត្រូវបង់ថ្លៃមេធាវីដោយខ្លួនឯងលើកលែងតែតុលាការសំរេចថាមិនអោយបង់។ ប្រសិនបើអ្នកទទួល បានលទ្ធផលជាទីគាប់ចិត្តជាលាយល័ក្ខអក្សរ ឬក៏ពីសវនាការ ឬពីតុលាការតុលាការ[17]អាចសំរេចថាសាលារៀនគួរតែចេញ ថ្លៃមេធាវីជំនួសអ្នក ។ សូមចំណាំផងដែរថា អ្នកមិនអាចទទួល យកតំលៃនេះបន្ទាប់ពីភាគីសាលាសំរេចធ្វើការដោះស្រាយរួច ហើយទេ ប្រសិនបើ

- សាលាបានផ្តល់សំណើរដោះស្រាយជាលាយល័ក្ខអក្សរក្នុងរយៈពេល១០ថ្ងៃ ឬ លើសពី១០ថ្ងៃមុនពេលថ្ងៃសវនាការ ចាប់ផ្តើម
- អ្នកមិនទទួលយកសំណើរនោះក្នុងរយៈពេល១០ថ្ងៃ និង
- លទ្ធផលនៃសវនាការនោះមិនប្រសើរជាងការដំណោះដោះស្រាយ។

ប្រសិនបើតំបន់សាលាទទួលបានការសម្រេចចិត្តជាទីពេញចិត្ត តុលាការអាចបញ្ជាឲ្យមេធាវីរបស់អ្នកបង់លើការចំណាយ ផ្លូវច្បាប់ របស់សាលាតំបន់ប្រសិនបើតុលាការរកឃើញថាមេធាវីរបស់អ្នកដាក់ពាក្យប្តឹង ឬបន្តប្តឹងបន្ទាប់ពីសិក្សាឃើញថា បណ្តឹង គ្មានមូលដ្ឋានពិតមិនមានហេតុផលឥតបានការ ឬបន្តក្នុងគោលបំណងមិនសមរម្យណាមួយ។ តុលាការក៏អាចបញ្ជាអ្នក ឬមេធាវីបង់លើចំណាយផ្លូវច្បាប់ដែរប្រសិនបើសំណើរបស់អ្នកសម្រាប់ដំណើរការសវនការ ឬបុព្វហេតុបន្តបន្ទាប់នៃសកម្មភាព ត្រូវបានបង្ហាញក្នុងគោលដៅមិនសមរម្យដូចជាដើម្បីបៀតបៀន ដើម្បីបង្កឲ្យមានការពន្យាមិនចាំបាច់ ឬដើម្បីបង្កើនតម្លៃប្តឹង ដែលមិនចាំបាច់។

តុលាការអាចបញ្ជាអ្នក ឬ មេធាវីរបស់អ្នកចេញថ្លៃរាល់ការចំណាយរបស់ភ្នាក់ងាររដ្ឋ ឬ សាលាតាមផ្លូវច្បាប់ ប្រសិនបើ តុលាការរកឃើញថា មេធាវីរបស់អ្នកដាក់ពាក្យបណ្តឹង ឬ បន្តរឿងក្តីបន្ទាប់ពីដឹងថាបណ្តឹងនោះធ្វើឡើងដោយគ្មានមូលដ្ឋាន អង្គហេតុ មិនមានមូលហេតុត្រឹមត្រូវ ឥត ប្រយោជន៍ និង ពុំមានគោល បំណងច្បាស់លាស់។

---

[16] សេចក្តីសំរេចរបស់សវនាការត្រូវបោះពុម្ពផ្សាយបន្ទាប់ពីប្រកាសអោយមានការផ្ទាងផ្ទាត់សិស្សរួចរាល់

[17] មន្ត្រីសវនាការមិនអាចចេញថ្លៃមេធាវីបានទេ

៦.តើអ្នកទទួលខុសត្រូវអ្វីខ្លះប្រសិនបើអ្នកអោយសិស្សចូលរៀនសាលាឯកជន និងប្រសិនបើអ្នកគិតថាសាលារៀនថ្នាក់ស្រុក គួរតែប្រគល់ថ្លៃឈ្នួនបង្រៀនអោយមកអ្នកវិញ?
**34CFR§300.148**

ក្នុងកាលទេសខ្លះ ឪពុកម្តាយមានជំនឿថា សាលារដ្ឋមិនផ្តល់កម្មវិធី **FAPE** ដល់សិស្ស ហើយឪពុកម្តាយសំរេចអោយកូន ចូលរៀនសាលាឯកជនវិញ។ ឪពុកម្តាយអាចចុះឈ្មោះកូនក្នុងសាលារៀនឯកជនបានដោយចំណាយថវិការផ្ទាល់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើឪពុកម្តាយជឿជាក់ថា សាលារៀនរដ្ឋគួរតែទទួលខុសត្រូវលើការចំណាយសំរាប់ ការសិក្សារបស់សិស្សនៅសាលា ឯកជន ឪពុកម្តាយត្រូវប្រាប់អំពីការជំទាស់របស់ខ្លួនមិនអោយកូនរៀនកម្មវិធី IEP និង កម្មវិធីផ្សេងទៀត ត្រូវច្រានចោលកម្មវិធី IEP ហើយ ត្រូវប្រាប់ទៅសាលាពីគោលបំណងដែលអ្នកដកកូនពីសាលាអោយទៅ ចុះឈ្មោះចូលរៀននៅសាលាឯកជន ហើយអ្នកត្រូវដាក់ពាក្យស្នើរសុំសវនាការមួយដែលរៀបចំឡើងដោយ BSEA ។
ឪពុកម្តាយត្រូវជូនដំណឹងដល់សាលាមុនពេលដែលអ្នកដកកូនចេញពីសាលានៅក្នុងអង្គប្រជុំចុងក្រោយដោយផ្ទាល់មាត់ ឬ ជាលាយល័ក្ខអក្សរក្នុងរយះពេល១០ថ្ងៃមុនពេលដកកូនចេញ។

សាលារៀនមិនអាចតំរូវអោយបង់ថ្លៃសិក្សារបស់កូនក្នុងសាលាឯកជននោះបានទេ ប្រសិនបើសាលារៀនមានកម្មវិធី FAPE សំរាប់បង្រៀនកូនរបស់អ្នកដែរនោះ ។ ការមិនចុះសំរុងគ្នាថាតើសាលារៀនរបស់រដ្ឋបាន ឬ មិនបានផ្តល់កម្មវិធី FAPE ដល់កូនអ្នក និងការស្នើរសុំថ្លៃសាលាឯកជនត្រូវដោះស្រាយតាមនិតិវិធីយុត្តិធម៌ដូចមានចែងខាងលើក្នុងឯកសារនេះស្រាប់ ។ មន្ត្រីសវនាការ និងរកមើលថាតើសាលារៀនថ្នាក់ស្រុកពិតជាមិនបានផ្តល់កម្មវិធី FAPE ដល់កូនអ្នកដែរទេ។ បើមន្ត្រីសវនាការរកឃើញថា សាលារៀនមិនបានផ្តល់កម្មវិធី FAPE ដល់កូនអ្នក ហើយចំណាត់ការខាងលើរបស់អ្នក និង ការបញ្ជូនកូនអោយទៅសិក្សាសាលាឯកជនពិតជាត្រឹមត្រូវនោះ បន្ទាប់ពីមានការពិចារណាគ្រប់កាលទេសនៃការដកកូន ចេញពីសាលារដ្ឋ មន្ត្រីសវនាការអាចតំរូវអោយសាលាត្រូវបង់ថ្លៃសិក្សានៅសាលាឯកជនទាំងអស់ ឬ បង់ថ្លៃក្នុងចំណែកណាមួយអោយមកអ្នកវិញ។

៧. តើត្រូវរៀបចំផែនការអ្វីខ្លះសំរាប់បញ្ជូនកូនអ្នកចេញពីសាលារៀន?

ការរៀបចំផែនការសំរាប់ការបញ្ជូនកូនរបស់អ្នកទៅវិទ្យាល័យត្រូវចាប់ផ្តើមតាំងពីពេលកូនរបស់អ្នកមានអាយុ ១៥ឆ្នាំ ហើយ ត្រូវមានការពិភាក្សាជារៀងរាល់ឆ្នាំ ។
សាលាក៏ត្រូវធ្វើការពិភាក្សាអំពីការបញ្ជូននេះជាមួយអ្នក និងជាមួយកូនរបស់អ្នកដែរ ។
អ្នកត្រូវតែពិចារណាពីគោលបំណងកូនរបស់អ្នកនៅពេលបញ្ចប់សាលារៀនឌីប្លូម ឬ

នៅពេលកូនមានអាយុ២២ឆ្នាំ ។ សាលារៀនថ្នាក់ស្រុកត្រូវប្រើប្រាស់បែបបទគំរូសំរាប់ផែនការបញ្ជូន[18] ដើម្បីកត់ត្រាលើការពិភាក្សាប្រចាំឆ្នាំ ។ កម្មវិធី IEP របស់សិស្សត្រូវរួមបញ្ចូលដូចជា គោលបំណងនៃការបញ្ជូនក្រោយមធ្យមសិក្សា ទិសដៅ និង សេវាកម្មដោយផ្អែកលើ ការវាយតំលៃ ពិការភាពរបស់សិស្ស និង តំរូវការនៃការបញ្ជូន។

ការបញ្ចប់សញ្ញាបត្រ័នៃវិទ្យាល័យ គឺជាការផ្លាស់ប្តូរកន្លែងសិក្សា ហើយជាពេលដែលត្រូវបញ្ចប់នូវសិទ្ធិទទួលបានការសិក្សា ពិសេស។ សាលារៀនថ្នាក់ស្រុកត្រូវជូនដំណឹងដល់អ្នក ប្រសិនបើនៅពេលសាលារៀនគិតថាកូនរបស់អ្នកនិងត្រូវបញ្ចប់ សញ្ញាបត្រ័នៃវិទ្យាល័យ។ ការពិភាក្សាជាមួយក្រុមការងារនឹងត្រូវចាប់ផ្តើមក្នុងរយៈពេល១ឆ្នាំយ៉ាងតិចមុនពេលសិស្សត្រូវ បញ្ចប់។

## ៨. តើសាលារៀនអាចដាក់វិន័យសិស្សពិការដោយវិធីណា?

**34CFR 300.350**

ផែនការនៃការផ្ទេរសិស្សរបស់អ្នកពីសាលាទៅក្រោយសាលានឹងជួយសម្រួលដល់សមត្ថភាពសិស្សរបស់អ្នកដើម្បី ចូលរួមដោយជោគជ័យក្នុងសកម្មភាពដូចជាការសិក្សាថ្នាក់ក្រោយធម្យមសិក្សា ការងារ និងសហគមន៍ និងជីវិតរបស់មនុស្ស ពេញវ័យ។ ផែនការក្នុងការផ្ទេរត្រូវតែផ្អែកលើភាពខ្លាំង ចំណង់ចំណូលចិត្ត ចំណាប់អារម្មណ៍ និងតម្រូវការរបស់សិស្ស ព្រមទាំង ត្រូវចាប់ផ្តើម ពេលដែលសិស្សមានអាយុ១៤ឆ្នាំ និងត្រូវតែពិភាក្សាជារៀងរាល់ឆ្នាំនៅក្នុងការប្រជុំក្រុម។ តំបន់សាលាត្រូវតែ ពិភាក្សាអំពីតម្រូវការ ក្នុងការផ្ទេរសាលារបស់សិស្សជាមួយអ្នក និងសិស្សរបស់អ្នក និងត្រូវតែពិចារណាលើគោលដៅសម្រាប់ សិស្សរបស់អ្នកបន្ទាប់ពីគាត់

សាលារៀនរដ្ឋត្រូវតែមាននិតិវិធី និង បទដ្ឋានដើម្បីធានាអោយមានបរិយាសកាសរៀនសូត្រប្រកបដោយសុវត្ថិភាពដល់ សិស្ស ។ គេរំពឹងថាសាលារៀន និងសាលាវិទ្យាល័យត្រូវបោះផ្សាយក្រមសីលធម៌ដើម្បីអោយសិស្សយល់ដឹងថាតើ គេត្រូវធ្វើ អកប្បកិរិយាដោយវិធីណា។ ប្រសិនបើសិស្សប្រព្រឹត្តិខុស ហើយរំលោភក្រមសីលធម៌របស់សាលា សាលាអាចដាក់ ពិន័យសិស្សនោះបាន ។ ការដាក់វិន័យត្រូវតែ ប្រកបដោយយុត្តិធម៌ និង អព្យាក្រឹត ។

ជាទូទៅ សិស្សម្នាក់ៗអាចប្រឈមមុខនឹងការដាក់វិន័យដូចជា ការបង្អាកការសិក្សា ឬ អោយចេញពីសាលារៀនក្នុងរយៈពេលខ្លី ហើយរយៈពេលនោះមិនត្រូវហួសពី ១០ថ្ងៃឡើយ ។ មុនពេល អោយចេញពីសាលា និង ផ្អាកការសិក្សាសិស្សម្នាក់ៗ ត្រូវដឹងថាតើខ្លួនទទួលរងការចោទប្រកាន់អ្វីខ្លះ ហើយត្រូវមានឱកាសសំរាប់រៀបរាប់រឿងរបស់ខ្លួន។ ក្នុងកំឡុងពេលបណ្តេញចេញពីសាលារៀន រយៈពេលខ្លី សាលារៀនមិនតំរូវអោយផ្តល់ការណែនាំដល់សិស្សពិការទេ ចំពោះសិស្សធម្មតាត្រូវមានការ ណែនាំ។ សរុបមក បើសិស្សពិការត្រូវបានដេញពីសាលារៀនមានរយៈពេល១០ថ្ងៃក្នុងមួយឆ្នាំសិក្សា

18 http://www.doe.mass.edu/sped/28MR/28m9.doc

សិស្សនោះត្រូវអនុញ្ញាតអោយទទួលសេវាកម្មចូលរៀនក្នុងកម្មវិធីសិក្សាទូទៅ ជាបន្ត ហើយធ្វើអោយសិស្សនោះនឹងសំរេចគោលដៅដែលមានចែងក្នុង IEP ។ មន្ត្រីរបស់សាលាត្រូវពិគ្រោះយោបល់ជាមួយគ្រូរបស់សិស្សអោយបានម្នាក់យ៉ាងតិច ដើម្បីកំណត់ថាតើសេវាកម្មអ្វីខ្លះ ដែលវាចាំបាច់ត្រូវតែផ្តល់អោយសិស្សនោះ ។ សេវាកម្មទាំងអស់នេះត្រូវចាប់ផ្តើមនៅថ្ងៃទី១១នៃការដាក់ពិន័យអោយចេញពីសាលា និងសេវាកម្មត្រូវផ្តល់ជាបន្តទៀតនៅពេលដែលការដាក់ពិន័យត្រូវបញ្ចប់ ។

សាលារៀនត្រូវអនុវត្តតាមបទបញ្ញាវិន័យពិសេសសំរាប់សិស្សពិការដែលមានសិស្សទទួលបានការអប់រំពិសេស។[19] តារាងសំរាប់ការដាក់ពិន័យនេះមានចុះផ្សាយនៅក្នុងគេហទំព័ររបស់ ESE ។[20] បទបញ្ញាដាក់ពិន័យនេះត្រូវអនុវត្តភ្លាមៗ សំរាប់សិស្ស ណាម្នាក់ដែលត្រូវបានបណ្តេញចេញកន្លែងដែលកំពុងតែសិក្សា[21] អស់រយះពេលជាង១០ថ្ងៃជាប់គ្នា ឬក៏សិស្សនោះត្រូវបាន គេបណ្តេញដោយសារការដាក់ពិន័យជាង១០ថ្ងៃក្នុងមួយឆ្នាំសិក្សា ហើយមានឯកសារសំរាប់ ប្រៀបធៀបផ្ទៀងផ្ទាត់មើលមូលហេតុនៃការបណ្តេញចេញ។ សាលារៀនត្រូវជូនដំណឹងដល់អ្នកជាបន្ទាន់នៅពេលសាលាធ្វើ សេចក្តីសំរេចបណ្តេញសិស្សចេញពីកន្លែងសិក្សាដែលមានរយះពេល១០ថ្ងៃ ហើយសាលាប្រគល់សេចក្តីជូនដំណឹងមួយច្បាប់នោះអោយអ្នក។

ក្រុមកម្មវិធី IEP របស់សិស្ស ត្រូវធ្វើការប្រជុំក្នុងរយះពេល ១០ថ្ងៃចាប់ពីថ្ងៃដែលធ្វើសេចក្តីសំរេចការដាក់ពិន័យដល់សិស្ស ។ ប្រជុំនេះ ហៅថា ក៉ារកំណត់បង្ហាញអង្គហេតុ manifestation determination ៉ អ្នក និងសមាជិកផ្សេងទៀតរបស់ក្រុម IEP នឹងត្រូវកំណត់ថាតើ ការប្រព្រឹត្តិខុសរបស់សិស្សបណ្តាលមកពីពិការភាពរបស់សិស្សនោះដែរទេឬក៏វាជាលទ្ធផលដែល បណ្តាលមកពីសាលាមិនបានផ្តល់សេវាកម្មដែលមាននៅក្នុងកម្មវិធី IEP ដល់សិស្ស ។ នៅក្នុងការកំណត់បង្ហាញអង្គហេតុនោះ អ្នកនឹងសមាជិករបស់ក្រុម IEP

---

[19] ច្បាប់ដាក់វិន័យក្នុងកម្មវិធីសិក្សាអប់រំពិសេស ក៏ត្រូវអនុវត្តសំរាប់សិស្សណាដែលមិនទាន់មានសិទ្ធិទទួលការអប់រំពិសេសនោះផងដែរ។ មុនពេល ធ្វើការសួរ ប្រសិនបើឪពុកម្តាយលើកយកការព្រួយបារម្មណ៍របស់សិស្សជាលាយលក្ខ័អក្សរទៅជូនថ្នាក់លើ ឬ បុគ្គលិករដ្ឋបាល ឬគ្រូរបស់សិស្សនោះថាសិស្សនោះប្រហែលជានឹងអាចមានពិការភាព ប្រសិនបើគ្រូ ឬបុគ្គលិកផ្សេងៗទៀតសំដែងការព្រួយបារម្មណ៍អំពីអកប្បកិរិយារបស់សិស្ស ជំរាបជូនទៅនាយកនៃកម្មវិធីអប់រំពិសេសនោះ ឬបុគ្គលិកគ្រប់គ្រងផ្សេងទៀត ប្រសិនបើសិស្សត្រូវបានគេយកទៅធ្វើការវាយតំលៃមិនទាន់ចប់សព្វគ្រប់បទបញ្ញាវិន័យពិសេសនេះត្រូវយកមកអនុវត្តបានដែរ។ បទបញ្ញាពិន័យពិសេសនេះមិនអាចអនុវត្តទេ ប្រសិនបើឪពុកម្តាយបដិសេធមិនយល់ព្រមអោយមានការវាយតំលៃ ឬ សិស្សធ្លាប់ត្រូវបានគេរកឃើញថាសិស្សនោះមិនមានសិទ្ធិទទួលបានការអប់រំពិសេសទេ។

[20] http://www.doe.mass.edu/sped/IDEA2004/spr_meetings/disc_chart.doc

[21] ជាកន្លែងសិក្សាដែលកំណត់ដោយក្រុម IEP និង ជាកន្លែងដែលទទួលសេវាកម្មពីIEP

ត្រូវពិចារណាលើពត៌មានដែលពាក់ពន្ធ័ទៅនឹងជីវិតរបស់សិស្សដែលមានរួមបញ្ចូលដូចជា កម្មវិធី IEP – ការសង្កេតរបស់អ្នក និងរបស់គ្រូលើអកប្បកិរិយារបស់សិស្ស និង ពត៌មានផ្សេងទៀតដែលអ្នកផ្តល់ជូនក្នុងអង្គប្រជុំ។

ប្រសិនបើក្រុមការងារកំណត់ថា អកប្បកិរិយារបស់សិស្ស មិនបណ្តាលមកពី ឬទាក់ទងផ្ទាល់ទៅនឹងពិការភាព ឬ មិនទាក់ទងទៅនឹងការខកខានមិនអនុវត្តកម្មវិធី IEP ទេ សិស្សដែលមានពិការភាពអាចត្រូវដាក់វិន័យដែលមានលក្ខណៈ និង រយៈពេលដូចការដាក់ពិន័យសិស្សផ្សេងទៀតដែលប្រព្រឹត្តិកំហុសដូចគ្នា ។ ទោះបីជាយ៉ាងណាក៏ដោយក្រុម IEP ត្រូវកំណត់ កន្លែងសិក្សាបណ្តោះអាសន្នសំរាប់សិស្ស (Interim Alternative Educational Setting-IAES) ដើម្បីអោយសិស្សបានសិក្សា និង ទទួលសេវាកម្មផ្សេងៗ ទៀតក្នុងកំឡុងពេលនៃការដាក់ពិន័យ ។ IAES គឺជា កន្លែងរៀបចំថ្មី ដើម្បីអោយសិស្សមានឱកាសរៀន និង ទទួលសេវាកម្មអប់រំជាបន្តដោយយោងទៅតាមកម្មវិធីIEPរបស់សិស្ស ។ បុគ្គលិករបស់សាលាពិចារណាលើកាលទេសនៃការប្តូរកន្លែងសិក្សាសំរាប់សិស្សពិការវាជាការសមរម្យឬយ៉ាងណា ។ ប្រសិនបើក្រុមកំណត់រកឃើញថាអកប្បកិរិយារបស់សិស្សបណ្តាលមកពី ឬទាក់ទងទៅផ្ទាល់ទៅនឹងពិការភាព ឬ នឹងការខកខានមិនអនុវត្តកម្មវិធី IEP សំរាប់សិស្សដែលមានពិការភាព ដូច្នេះសិស្សត្រូវបញ្ជូនទៅកន្លែងដើមដែលមានកម្មវិធី IEP លើកលែងតែអ្នក និងក្រុមការងារសំរេចអោយទៅរៀនកន្លែងផ្សេងវិញ។ សិស្សត្រូវតែទទួលបានពត៌មាន ស្តីពីការវាយតំលៃអំពីអកប្បកិរិយារបស់ខ្លួន។ ការវាយតំលៃ អកប្បកិរិយារបស់សិស្សនោះ ឬ FBA គឺជាការវាយតំលៃទូទៅផ្តល់ពត៌មានអំពីអត្តចរិកសិស្សជូនដល់ក្រុម IEP និង អំពីសេវាកម្ម អន្តរាគមន៍ផ្នែកអកប្បកិរិយា និងកម្មវិធីកែប្រែដែលត្រូវរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងអកប្បកិរិយាហឹង្សាកុំអោយវាកើតឡើងពេលក្រោយទៀត។ ប្រសិនបើសិស្សបានទទួលការវាយតំលៃអកប្បកិរិយារួច និង ទទួលការអប់រំខាងផ្នែកអន្តរាគមន៍អកប្បកិរិយាក្រុម IEP ត្រូវពិចារ ណាលើការកែប្រែផែនការ អន្តរាគមន៍អកប្បកិរិយាអោយបានល្អ ។ ប្រសិនបើអកប្បកិរិយា នោះបណ្តាលមកពីការបរាជ័យមិនបានអនុវត្តកម្មវិធី IEP អោយបានត្រឹមត្រូវទេ សាលារៀនត្រូវចាត់វិធាន ការដោះស្រាយដើម្បីធ្វើអោយកម្មវិធីនោះមានប្រសិទ្ធិភាពភ្លាម។

សូមចំណាំថា ប្រសិនបើសិស្សមាន ឬប្រើប្រាស់អាវុធ ថ្នាំញៀន ឬ បណ្តាលអោយមានរបួលលើរាងកាយអ្នកដ៏ទៃនៅក្នុងបរិវេណសាលា ឬ នៅក្នុងព្រឹត្តិការណ៍សាលា នាយកសាលាត្រូវបញ្ជូនសិស្ស នោះអោយទៅសិក្សានៅកន្លែងកម្មវិធីអប់រំបណ្តោះអាសន្ន រហូតដល់៤៥ថ្ងៃនៃថ្ងៃសិក្សាដោយមិនបាច់គិតអំពីការកំណត់អំពីពិការភាពរបស់សិស្សឡើយ។ ក្រុម IEP និងកំណត់ ថាតើត្រូវមានការផ្តល់កម្មវិធីអប់រំបណ្តោះអាសន្ន និង សេវាកម្មអប់រំសមរម្យដល់សិស្សដែលគេបញ្ជូនទៅកន្លែង អប់រំបណ្តោះអាសន្នទេ។

## ៨.១ ការប្តឹងជំទាស់នឹងសេចក្តីសំរេចដាក់វិន័យ

ប្រសិនបើឪពុកម្តាយមិនយល់ព្រមចំពោះសេចក្តីសំរេចក្នុងការប្តូរកន្លែងសិក្សាដោយសារការដាក់ពិន័យ ឬ មិនយល់ព្រមការកំណត់បង្ហាញអង្គហេតុ ឬក៍សាលាជឿជាក់ថា
ការអនុញ្ញាតអោយសិស្សនៅរៀនកន្លែងដ៍ដែលទំនងជាធ្វើអោយសិស្ស ផ្សេងៗរងរបួស ឪពុកម្តាយ ឬ សាលារៀនអាចប្តឹងជំទាស់នឹងសេចក្តីសំរេចនោះដោយស្នើរសុំសវនាការជាមួយ BSEA ដូចដែល មានថែងខាង លើក្នុងឯកសារនេះស្រាប់។
BSEA នឹងរៀបចំសវនាការមួយស្តីអំពីការដាក់វិន័យ ឬការកំណត់បង្ហាញអង្គហេតុដោយរស់រាន់[22] ។
ក្នុងកំឡុងពេលប្តឹងជំទាស់ទៅនឹងការដាក់ពិន័យការកំណត់បង្ហាអង្គហេតុសិស្សត្រូវស្ថិនៅក្នុងកម្មវិធី IAES រហូតដល់មន្ត្រីសវនាការធ្វើសេចក្តីសំរេច ឬរយះពេលនៃការដាក់វិន័យត្រូវបញ្ចប់ ឬក៍ឪពុកម្តាយ និងសាលារៀនមានការព្រមព្រៀងគ្នាលើការផ្លាស់ប្តូរការសិក្សាថ្មី។

## ៩. តើអាចស្វែងរកច្បាប់ បទបញ្ញា និង ពត៍មានសំខាន់ៗនៅកន្លែងណាបាន?

## ៩.១ ច្បាប់ និង បទបញ្ញា

អ្នកអាចស្វែងរកអត្ថបទច្បាប់ស្តីអំពីការអប់រំពិសេសរបស់រដ្ឋនៅក្នុងច្បាប់ទូទៅរបស់ Massachusetts 71B។ ច្បាប់របស់រដ្ឋនេះ ត្រូវបានគេស្គាល់ថា Chapter 766 ។ បទបញ្ញាអប់រំពិសេស
អាចរកឃើញនៅក្នុងក្រមនៃបបទបញ្ញា Massachusetts (CMR) 603CMR28.00. ច្បាប់និងបទបញ្ញា ព្រមទាំងពត៍មានផ្សេងៗទៀតមាននៅក្នុងគេហទំព័រ ESE។[23]
ច្បាប់អប់រំពិសេសរបស់សហព័ន្ធ គឺជាច្បាប់អប់រំសំរាប់បុគ្គលដែលមានពិការភាពដែលគេស្គាល់ថា "IDEA"។ ល័ក្ខន្តិក: សហពន្ធ័ មាននៅក្នុងក្រមរបស់សហរដ្ឋ 20U.S.C §1400។ បទបញ្ញាអនុវត្តសំរាប់ IDEA មាននៅក្នុងក្រមបទបញ្ញាសហពន្ធ័ (CFR) ជំពូកទី៣៤ ផ្នែក ៣០០។ ពត៍មានពិស្តារអំពីច្បាប់ បទបញ្ញាមាននៅក្នុងគេហទំព័រនៃក្រសួងអប់រំរបស់សហរដ្ឋ http://idea.ed.gov ។

## ៩.២ គោលការណ៍ណែនាំកម្មវិធីអប់រំឯកជន និង បែបបទផ្សេងៗ

ដើម្បីចង់ដឹងថាតើ ដំណើរការអប់រំពិសេសនេះប្រព្រឹត្តទៅដូចម្តេច (ដកស្រង់ពីគោលការណ៍ IEP ដែលរៀបចំដោយ USDOE) មាននៅក្នុងគេហទំព័រ ESE : htt;://www.doe..mass.edu/sped/iep

## ៩.៣ តារាងអក្សរកាត់

មានឃ្លាជាច្រើនត្រូវគេសរសេរជាអក្សរកាត់។
ដើម្បីធ្វើអោយងាយស្រួលចំណាំខាងក្រោមនេះគឺជាអក្សរកាត់ដែលមាននៅ ក្នុងឯកសានេះ។

---

[22] សូមមើល ច្បាប់សវនាការ BSEA II.C. http://www.doe.mass.edu/bsea/forms/hearing_rules.doc p.6

[23] http://www.doe.mass.edu/sped/laws.html

BSEA: Bureau of Special Education Appeals ការិយាល័យតវ៉ាផ្នែកអប់រំពិសេស

CFR: Code of Feral Regulations ក្រមបទបញ្ញាសហព័ន្ធ

CMR: Code of Massachusetts Regulation ក្រមបទបញ្ញាសហព័ន្ធ

ESE: Massachusetts Department of Elementary and Secondary Education មន្ទីរអប់រំបឋមសិក្សា និងអនុវិទ្យាល័ Massachusetts

FAPE: Free Appropriate Public Education ការអប់រំសាធារណៈដោយឥតគិតថ្លៃ

FBA : Functional Behavioral Assessment ការវាយតំលៃអកប្បកិរិយា

IAES: Interim Alternative Education Setting កន្លែងសិក្សាបណ្ដោះអាសន្ន

IDEA: Individuals with Disabilities Education Act ច្បាប់អប់រំសំរាប់មនុស្សពិការ

IEE: Independent Educational Evaluation ការវាយតំលៃការអប់រំដោយឯករាជ

IEP: Individualized Education Program កម្មវិធីអប់រំលក្ខណៈបុគ្គល

PQA: Program Quality Assurance Services កម្មវិធីសេវាកម្មធានាគុណភាព

## ៩.៤ តារាងគេហទំព័រ

ការអប់រំថ្នាក់បឋម និងមធ្យម(ESE) ផ្សព្វផ្សាយព័ត៌មានទូលំទូលាយដល់មាតាបិតាសិស្ស និងតំបន់សាលាស្ដីអំពីគេហទំព័រ របស់ខ្លួន។ គេហទំព័រទាំងនេះរួមមាន ច្បាប់ដែលពាក់ព័ន្ធនឹងបញ្ហាកំពុងប្រឈម គោលនយោបាយទីភ្នាក់ងារ និងឯកសារមានប្រយោជន៍ដែលពន្យល់ពីដំណើការនៃការអប់រំពិសេស។

ការិយាល័យតវ៉ាអប់រំពិសេស

http://www.doe.mass.edu/bsea/decisions.html
http://www.doe.mass.edu.bsea/forms/hearing_rules.doc
http://www.doe.mass.edu.bsea/forms/hearing.doc
http://www.doe.mass.edu.bsea/mediation.html
http://www.doe.mass.edu.bsea/forms/hearing_rules.doc
http://www.doe.mass.edu.bsea/mediation.html?section=fag
http://www.doe.mass.edu.bsea/process.html

វិន័យ http://www.doe.mass.edu/sped/IDEA2004/spr_meetings/disc_chart.do

ច្បាប់ស្ដីពីមនុស្សពិការ http://www.idea.ed.gov/

ដំណើការនៃការអប់រំពិសេសក្រោម IDEA

http://www.doe.mass.edu/sped/iep/process.doc

កម្មវិធីអប់រំលក្ខណៈបុគ្គល http://www.doe.mass.edu/sped/iep

សេចក្ដីណែនាំស្ដីពីដំណើការនៃកម្មវិធីអប់រំសម្រាប់បុគ្គល

http://www.doe.mass.edu/sped/iep/proguide.pdf

ការវាយតំលៃការអប់រំឯករាជ http://www.doe.mass.edu/sped/advisories/?section=admin

ការសង្កេតនៃកម្មវិធីអប់រំដោយមាតាបិតាសិស្ស និងអ្នកបង្ហាញសម្រាប់គោលដៅវាយតម្លៃ
http://www.doe.mass.edu/sped/advisories/09_2.html

សេចក្តីជូនដំណឹងដល់មាតាបិតាស្តីអំពីនិតិវិធីការពារ http://www.doe.mass.edu/sped/prb

ការប្រៀបធៀបសំនួរចំលើយទៅនឹងដំណើការបណ្តឹងដោយយុត្តិធម៌
http://www.doe.mass.edu/sped.docs.html
ប្រពន្ធ័ដោះស្រាយបញ្ហា និង កម្មវិធីសេវាកម្មធានាគុណភាព http://www.doe.mass.edu/pqa/prs
បទបញ្ជានឹងច្បាប់អប់រំពិសេស http://www.doe.mass.edu/sped/law/html
Special Education Surrogate Parent:
http://www.doe.mass.edu/sped/2002/news/1104memo.html

បែបបទរៀបចំផែនអប់រំសំរាប់បញ្ជូន http://www.doe.mass.edu/sped/28MR/28m9.doc
បទបញ្ជាកំណត់ហេតុសិស្ស http://www.doe.mass.edu/lawregs/603cmr23.html
សំនួរចំលើយកំណត់ហេតុសិស្ស http://www.doe.mass.edu/lawsregs/advisory/cmr23ganda.html?section
Transition Planning: ផែនការផ្ទេរសាលា
http://www.doe.mass.edu/sped/cspd/mod4.html#